# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ ខែ និង ១២ ខែ
## គិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩
## និង
## របាយការណ៍របស់សវនករឯករាជ្យ

# ព័ត៌មានអំពីក្រុមហ៊ុន

| | |
|---|---|
| ក្រុមហ៊ុន | **អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី** |
| ចុះបញ្ជីពាណិជ្ជកម្មលេខ | ០០០១២៨២៩ |
| ទីស្នាក់ការ | អាគារលេខ ៦៦៦B ផ្លូវលេខ ២៧១ សង្កាត់បឹងទំពុនទី២<br>ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| ភាគទុនិក | LOLC Private Limited<br>TPC-ESOP Co.. Ltd. |
| ក្រុមប្រឹក្សាភិបាល | លោក Brindley Chrishantha Gajanayake de Zylva, ប្រធានក្រុមប្រឹក្សាភិបាល<br>លោក Indrajith Wijesiriwardana, សមាជិក<br>លោក Hans Michael Theodor Moormann, សមាជិក<br>លោក Dulip Rasika Samaraweera, សមាជិក<br>លោក Francisco Kankanamalage Conrad Prasad Nirosh Dias, សមាជិក |
| គណៈកម្មាធិការសវនកម្ម | លោក Hans Michael Theodor Moormann, ប្រធាន<br>លោក Brindley Chrishantha Gajanayake de Zylva, សមាជិក<br>លោក Indrajith Wijesiriwardana, សមាជិក |
| គណៈកម្មាធិការគ្រប់គ្រងហានិភ័យ | លោក Hans Michael Theodor Moormann, ប្រធាន<br>លោក Brindley Chrishantha Gajanayake de Zylva, សមាជិក<br>លោក Francisco Kankanamalage Conrad Prasad Nirosh Dias, សមាជិក |
| គណៈកម្មាធិការតែងតាំង និងផ្តល់តម្លៃការ | លោក Indrajith Wijesiriwardana, ប្រធាន<br>លោក Dulip Rasika Samaraweera, សមាជិក<br>លោក Francisco Kankanamalage Conrad Prasad Nirosh Dias, សមាជិក |

## ព័ត៌មានអំពីក្រុមហ៊ុន (ត)

| | |
|---|---|
| គណៈកម្មាធិការប្រតិបត្តិ | លោក សុខ វឿន, ប្រធាននាយកប្រតិបត្តិ |
| | លោក សុខ សុផល, អនុប្រធាននាយកប្រតិបត្តិ/ប្រធាននាយកហិរញ្ញវត្ថុ |
| | លោក Damburae Liyanage Duleep Roshan, ប្រធាននាយកបច្ចេកវិជ្ជាព័ត៌មាន |
| | អ្នកស្រី ស៊ឹយ សុឌីណា, ប្រធាននាយិកាគ្រប់គ្រងហានិភ័យ |
| | លោក Mr. Romesh Perera, ប្រធាននាយកបណ្ដាញចែកចាយ |
| | អ្នកស្រី ឈាង កញ្ញា, ប្រធាននាយិកាឌីជីថល សេវាហិរញ្ញវត្ថុ និងប្រាក់បញ្ញើ |
| | អ្នកស្រី ឡេង ថាវី, នាយិកានាយកដ្ឋានធនធានមនុស្ស |
| | អ្នកស្រី កែវ តារាទី, នាយិកានាយកដ្ឋានហិរញ្ញវត្ថុ |
| | អ្នកស្រី ទ្រី សូឡា, នាយិកានាយកដ្ឋានរតនាគារ |
| | លោក សៀម ហាក់, នាយកនាយកដ្ឋានរដ្ឋបាល និងធុរកិច្ច |
| | លោក ហ៊ុល សុវត្ថា, នាយកនាយកដ្ឋានបច្ចេកវិជ្ជាព័ត៌មាន |
| | លោក ឈួន សុខចិត្ត, នាយកនាយកដ្ឋានទីផ្សារ |
| | លោក តេង ភាព, នាយកនាយកដ្ឋានសវនកម្មផ្ទៃក្នុង |
| | លោក បាន ផលឡេង, នាយកនាយកដ្ឋានប្រតិបត្តិតាម |
| | លោក នុត ថេង, នាយកនាយកដ្ឋានអាជីវកម្ម |
| | លោក មុត ពិសី, នាយកនាយកដ្ឋានឥណទាន |
| | លោក យិន ផល្លី, នាយកនាយកដ្ឋានឥណទានសម្ភារប្រើប្រាស់ (ចូលបម្រើការងារ នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩) |
| | លោក ទុន កង នាយករងនាយកដ្ឋានឥណទាន |
| សវនករ | ខេភីអឹមជី ខេមបូឌា ចំកាត់ |

**អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី**

## មាតិកា


| | | ទំព័រ |
|---|---|---|
| ១ | របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | ១ |
| ២ | របាយការណ៍របស់សវនករឯករាជ្យ | ៦ |
| ៣ | របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល | ៨ |
| ៤ | របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល | ១១ |
| ៥ | របាយការណ៍ស្តីពីបម្រែបម្រួលមូលធនសង្ខេបចន្លោះពេល | ១៣ |
| ៦ | របាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល | ១៤ |
| ៧ | កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល | ១៦ |

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល មានសេចក្តីសោមនស្សរីករាយធ្វើការបង្ហាញនូវរបាយការណ៍របស់ខ្លួន ព្រមទាំងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន **អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី** ហៅកាត់ថា (ក្រុមហ៊ុន) ដែលបានធ្វើការត្រួតពិនិត្យចដំណាច់ការិយបរិច្ឆេទ ៣ខែ និង១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ។

## សកម្មភាពចម្បង

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺផ្តល់សេវាកម្មមីក្រូហិរញ្ញវត្ថុ (ទទួលប្រាក់បញ្ញើ និងផ្តល់ឥណទាន) ដល់ប្រជាជនកម្ពុជានៅតាមជនបទ និងសហគ្រាសខ្នាតតូច និងសហគ្រាសខ្នាតមធ្យម តាមរយៈទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ និងសាខានានានៅតាមបណ្តាខេត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ក្នុងអំឡុងការិយបរិច្ឆេទនៃរបាយការណ៍ ពុំមានការផ្លាស់ប្តូរអ្វីគួរឲ្យកត់សម្គាល់ចំពោះសកម្មភាពចម្បងរបស់ក្រុមហ៊ុនទេ។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ត្រូវបានបង្ហាញដូចខាងក្រោម៖

| | ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | | ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៤) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៤) |
| ប្រាក់ចំណេញមុនដកពន្ធ | ១៥៨.៦៨៨.៩២៣ | ៣៩.១៣៤.១៣៥ | ៧៨.៥៤១.៧៧៨ | ១៩.៤២១.៨០៤ |
| ចំណាយពន្ធលើប្រាក់ចំណេញ | (១៧.២៦៦.០៧២) | (៤.២៥៧.៩៧១) | (២០.៧៤៧.៩២២) | (៥.១៣០.៥៤៥) |
| ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ | ១៤១.៤២២.៨៥១ | ៣៤.៨៧៦.១៦៤ | ៥៧.៧៩៣.៨៥៦ | ១៤.២៩១.២៥៩ |



ការិយាល័យកណ្តាល
អគារលេខ ៦៦៦ឃ ផ្លូវលេខ២៧១ ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទលេខ៖ (+៨៥៥) ២៣ ៩៩១ ៩៩១ | អ៊ីម៉ែល៖ info@lolc.com.kh
គេហទំព័រ៖ www.lolc.com.kh | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ | គ្រឹះស្ថានឯកជន

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## ភាគលាភ

ពុំមានការប្រកាស ឬការបែងចែកភាគលាភទេ ហើយក្រុមប្រឹក្សាភិបាលក៏មិនបានផ្តល់អនុសាសន៍ឲ្យមានការបែងចែកភាគលាភ ដំណាច់ការិយបរិច្ឆេទនេះទេ។

## ដើមទុន

នៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ ក្រុមហ៊ុន បានធ្វើលិខិតស្នើសុំទៅធនាគារជាតិនៃកម្ពុជា ដើម្បីបង្កើនដើមទុនដល់ ២២៨.៣៧៧.៩០០ ពាន់រៀល (ស្មើនឹង ៥៥.៨៤៩.៧៨៦ ដុល្លារអាមេរិក) ។ សំណើសុំនេះត្រូវបានអនុម័តដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៩ ។

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តលើទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ ។

## ឥណទានអាក្រក់ និងឥណទានជាប់សង្ស័យ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្រប ដើម្បីបញ្ជាក់ថាវិធានការទាក់ទងទៅនឹងការលុបចោលឥណទានអាក្រក់ និងការធ្វើសំវិធានធន លើឥណទានជាប់សង្ស័យ ត្រូវបានធ្វើឡើងដោយអ្នកគ្រប់គ្រង ឬក្រុមហ៊ុន ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថា រាល់ឥណទានដែលបានដឹងថាមិនអាចទាមទារបាន ត្រូវបានលុបចោល ហើយសំវិធានធនត្រូវបានធ្វើឡើងយ៉ាងគ្រប់គ្រាន់សម្រាប់ឥណទានដែលអាក្រក់ និងជាប់សង្ស័យ ។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយដែលថា ចំនួនឥណទានអាក្រក់ដែលបានលុបចេញពីបញ្ជី ឬចំនួនសំវិធានធនលើឥណទានជាប់សង្ស័យក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុនមានចំនួនមិនគ្រប់គ្រាន់ជាសារវន្តនោះទេ ។

## ទ្រព្យសកម្មចរន្ត

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុនត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្រប ដើម្បីធានាថា បណ្តាទ្រព្យសកម្មចរន្តទាំងអស់ ក្រៅពីបំណុល ដែលទំនងជាមិនអាចទទួលស្គាល់ក្នុងដំណើរការអាជីវកម្មធម្មតា នូវតម្លៃដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុនត្រូវបានកត់ត្រានូវតម្លៃដែលគិតថានឹងអាចដឹងបាន។

នាកាលបរិច្ឆេទចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលមិនបានដឹងអំពីហេតុការណ៍ណាមួយដែលនឹងបង្ហាញពីតម្លៃដែលត្រូវបានកំណត់ចំពោះទ្រព្យសកម្មចរន្តក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ថាមានភាពមិនត្រឹមត្រូវនោះទេ។

## អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

### វិធីសាស្ត្រកំណត់តម្លៃ

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើង ដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្ត្រដែលមានកន្លងមក ក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ ។

### បំណុលយថាហេតុ និងបំណុលផ្សេងៗ

នាថ្ងៃចេញរបាយការណ៍នេះ គឺពុំមាន៖

(ក) ការចំណាយណាមួយលើទ្រព្យសកម្មរបស់ក្រុមហ៊ុន ដែលកើតមានឡើងចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាមួយឡើយ ឬ

(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះក្រុមហ៊ុន ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទមក ក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ក្រុមហ៊ុន ។

យោងតាមការយល់ឃើញរបស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ក្រុមហ៊ុនដែលនឹងត្រូវបានទាមទារ ឬអាចនឹងត្រូវបានទាមទារក្នុងរយៈពេល ១២ ខែបន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ដែលនឹងធ្វើឲ្យមានផលប៉ះពាល់ ឬអាចនឹងប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដូចដែលបានកំណត់នាកាលបរិច្ឆេទកំណត់សង ។

### ការផ្លាស់ប្តូរនៃហេតុការណ៍

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលមិនបានបង្ហាញនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលរបស់ក្រុមហ៊ុន ដែលនឹងបណ្តាលឲ្យមានតួលេខនៃចំនួនណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលមានភាពមិនត្រឹមត្រូវនោះទេ ។

### ប្រការមិនប្រក្រតី

យោងតាមការយល់ឃើញរបស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃការធ្វើប្រតិបត្តិការរបស់ក្រុមហ៊ុន ក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុសង្ខេបចន្លោះពេលនេះ មិនមានផលប៉ះពាល់ជាសារវន្តដោយសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ ។

ក្រុមប្រឹក្សាភិបាលក៏មានមតិផងដែរថា នៅក្នុងចន្លោះពេលចាប់ពីកាលបរិច្ឆេទដល់ថ្ងៃចេញរបាយការណ៍នេះ ពុំមានចំណាត់ថ្នាក់សកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើង ដែលអាចនាំឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុន ក្នុងការិយបរិច្ឆេទដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ ។

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## ព្រឹត្តិការណ៍បន្ទាប់ពីថ្ងៃចេញរបាយការណ៍

នាថ្ងៃចេញនៃរបាយការណ៍នេះ ពុំមានព្រឹត្តិការណ៍អ្វីគួរឲ្យកត់សម្គាល់ណាមួយកើតឡើងទេ បន្ទាប់ពីថ្ងៃចេញរបាយការណ៍ដែលតម្រូវឲ្យមានការកែតម្រូវ ឬលាតត្រដាងព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុចន្លោះពេលនេះទេ ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលដែលបានបម្រើការក្នុងអំឡុងការិយបរិច្ឆេទ និងនាថ្ងៃចេញរបាយការណ៍នេះរួមមាន៖

| | |
|---|---|
| លោក Brindley Chrishantha Gajanayake de Zylva | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក Indrajith Wijesiriwardana | សមាជិក |
| លោក Hans Michael Theodor Moormann | សមាជិក |
| លោក Dulip Rasika Samaraweera | សមាជិក |
| លោក Francisco Kankanamalage Conrad Prasad Nirosh Dias | សមាជិក |

## ចំណាប់អារម្មណ៍របស់ក្រុមប្រឹក្សាភិបាល

ពុំមានអភិបាលណាមួយ គ្រប់គ្រងលើមូលធន របស់ក្រុមហ៊ុនទេ ។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

ចាប់តាំងពីចុងបញ្ចប់នៃការិយបរិច្ឆេទហិរញ្ញវត្ថុគ្រាមុន គ្មានអភិបាលណាមួយរបស់ក្រុមហ៊ុនបានទទួល ឬមានសិទ្ធិទទួលបានអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានរាប់បញ្ចូលក្នុងចំនួនសរុប ដែលទទួលបានដោយក្រុមប្រឹក្សាភិបាលដែលត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមមូលហេតុនៃកិច្ចសន្យាដែលធ្វើឡើងដោយក្រុមហ៊ុន ឬពាក់ព័ន្ធជាមួយក្រុមហ៊ុនដែលអភិបាលជាសមាជិក ឬជាមួយក្រុមហ៊ុនដែលអភិបាលមានអត្ថប្រយោជន៍ផ្នែកហិរញ្ញវត្ថុ ក្រៅពីអ្វីដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះទេ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ត្រូវបានរៀបចំគ្រប់ទិដ្ឋភាពជាសារវន្ត ស្របតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា ៣៤ "របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល"។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលត្រូវ៖

(i) អនុវត្តគោលនយោបាយគណនេយ្យសមស្រប ដែលគាំទ្រដោយការវិនិច្ឆ័យ និងការប៉ាន់ប្រមាណសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ព្រមទាំងអនុវត្តតាមគោលនយោបាយទាំងនេះប្រកបដោយសង្គតិភាព។

## អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

### ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ (ត)

(ii) អនុលោមតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា 34 "របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល" ឬប្រសិនបើមានការប្រាសចាកណាមួយ ដើម្បីបង្ហាញពីភាពត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលត្រូវប្រាកដថាការប្រាសចាកទាំងនោះត្រូវបានបង្ហាញ ពន្យល់ និងកំណត់ចំនួនទឹកប្រាក់ឲ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ។

(iii) អនុលោមតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា ៣៤ "របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល" ឬប្រសិនបើមានការប្រាសចាកណាមួយ ដើម្បីបង្ហាញពីភាពត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលត្រូវប្រាកដថាការប្រាសចាកទាំងនោះត្រូវបានបង្ហាញ ពន្យល់ និងកំណត់ចំនួនទឹកប្រាក់ឲ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ។

(iv) ត្រួតពិនិត្យប្រព័ន្ធដំណើរការរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងរក្សាទុកកំណត់ត្រាគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព ។

(v) វាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ការលាតត្រដាងព័ត៌មាន បញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែគណៈគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជីផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ ។

(vi) ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឲ្យមានប្រសិទ្ធភាពលើរាល់ការសម្រេចចិត្តដែលអាចមានផលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថាការត្រួតពិនិត្យនេះត្រូវបានឆ្លុះបញ្ចាំងភាពត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលអះអាងថា ក្រុមហ៊ុនបានអនុវត្តតាមតម្រូវការខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

### ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

ខ្ញុំ តាងនាមឲ្យក្រុមប្រឹក្សាភិបាល សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលសម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ និង១២ខែ គិតត្រឹម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ដូចបានបង្ហាញនៅទំព័រទី ៨ ដល់ទី ៧៩ ថាត្រូវបានរៀបចំឡើង ដោយអនុលោមតាមស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា ៣៤ "របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល" ។

*ចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សាភិបាល៖*

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី
LOLC (CAMBODIA) Plc.
KINGDOM OF CAMBODIA

Brindley Chrishantha Gajanayake de Zylva
*ប្រធានក្រុមប្រឹក្សាភិបាល*
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០

KPMG

KPMG Cambodia Ltd
4th Floor, Delano Center
No. 144, Street 169, Sangkat Veal Vong
Khan 7 Makara, Phnom Penh
Kingdom of Cambodia
+855 23 216 899 | kpmg.com.kh

# របាយការណ៍របស់សវនករឯករាជ្យ

## ជូនចំពោះភាគទុនិក
## អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

### *សេចក្តីផ្តើម*

យើងខ្ញុំ បានធ្វើការត្រួតពិនិត្យលើរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល របស់ **អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី** ហៅកាត់ថា (ក្រុមហ៊ុន) នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ និងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល របាយការណ៍ស្តីពីបម្រែបម្រួលមូលធនសង្ខេបចន្លោះពេល និងលំហូរទឹកប្រាក់សង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ និង ១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ និងកំណត់សម្គាល់ផ្សេងៗទៀតដែលបានបង្ហាញនៅទំព័រទី ៨ ដល់ទី ៧៩ ហៅកាត់ថា (របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល)។ គណៈគ្រប់គ្រង មានភារៈទទួលខុសត្រូវលើការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដោយអនុលោមតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា ៣៤ "របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល" ។ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺផ្តល់ការសន្និដ្ឋានលើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលដោយផ្អែកលើការធ្វើការត្រួតពិនិត្យរបស់យើងខ្ញុំ ។

### *ទំហំនៃការត្រួតពិនិត្យ*

យើងខ្ញុំ បានធ្វើការត្រួតពិនិត្យលើរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាមស្តង់ដារអន្តរជាតិនៃកម្ពុជាសម្រាប់កិច្ចព្រមព្រៀងត្រួតពិនិត្យ លេខ ២៤១០ "ការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុចន្លោះពេល ដែលអនុវត្តដោយសវនករឯករាជ្យរបស់ក្រុមហ៊ុន" ។ ការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុចន្លោះពេល រួមមានការសាកសួរព័ត៌មាន ជាពិសេសសាកសួរបុគ្គលដែលមានភារៈទទួលខុសត្រូវលើបញ្ហាគណនេយ្យ និងហិរញ្ញវត្ថុ និងធ្វើការវិភាគ និងនីតិវិធីត្រួតពិនិត្យផ្សេងៗ។ ការត្រួតពិនិត្យលើព័ត៌មានហិរញ្ញវត្ថុចន្លោះពេលមានទំហំតូចជាងការធ្វើសវនកម្ម ដែលអនុលោមតាម ស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ហេតុដូច្នេះ វាមិនអាចឲ្យយើងខ្ញុំ ផ្តល់នូវអំណះអំណាងថា យើងខ្ញុំបានស្វែងយល់អំពីបញ្ហាជាសារវន្តទាំងអស់ ដែលអាចនឹងត្រូវបានរកឃើញក្នុងពេលធ្វើសវនកម្មបានឡើយ ។ ហេតុដូច្នេះយើងខ្ញុំ មិនបញ្ចេញមតិសវនកម្មនោះទេ ។

KPMG Cambodia Ltd, a Cambodian limited liability company and a member firm of the KPMG network of independent member firms affiliated with KPMG International Cooperative ("KPMG International"), a Swiss entity.
Document classification: KPMG Confidential

KPMG

### *ការសន្និដ្ឋាន*

ផ្អែកលើការត្រួតពិនិត្យរបស់យើងខ្ញុំ ពុំមានបញ្ហាណាមួយទាញចំណាប់អារម្មណ៍របស់យើងខ្ញុំ ដែលបណ្តាលឲ្យយើងខ្ញុំជឿថា របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ និង ១២ខែ គិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩ មិនត្រូវបានរៀបចំគ្រប់ទិដ្ឋភាពជាសារវន្ត ស្របតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា ៣៤ "របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល" នោះទេ ។

### *បញ្ហាផ្សេងៗ*

យើងខ្ញុំសូមទាញចំណាប់អារម្មណ៍ថា យើងខ្ញុំពុំបានត្រួតពិនិត្យ របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងលំហូរទឹកប្រាក់សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ គិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៨ ឬកំណត់សម្គាល់ណាមួយដែលពាក់ព័ន្ធឡើយ ដូច្នេះយើងខ្ញុំមិនផ្តល់ការសន្និដ្ឋាន ឬផ្តល់នូវអំណះអំណាងណាមួយទៅលើរបាយការណ៍ទាំងនោះឡើយ ។

តំណាងក្រុមហ៊ុន **ខេភីអឹមជី ខេមបូឌា ចំកាត់**

**ខែ ហ៊ុយ**

*Partner*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល

## នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

| | កំណត់សម្គាល់ | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | | នាថ្ងៃទី១ ខែមករា ឆ្នាំ២០១៨ | |
|---|---|---|---|---|---|---|---|
| | | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៤) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៤) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៤) |
| **ទ្រព្យសកម្ម** | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | ២៣ | ១០៥.១៨៥.៥៨១ | ២៥.៨១២.៩១៣ | ៤៩.០១៩.៣៩៣ | ១២.១៩៩.៩៤៨ | ១៨.២០១.៥៥៦ | ៤.៥០៨.៦៨៤ |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | ៦ | ៧៥៨.០១៩.៤៦១ | ១៨៦.០១៧.០៤៦ | ៣១៧.៥២២.៧៤៦ | ៧៩.០២៥.០៧៤ | ៦២.១០៤.០៤៦ | ១៥.៣៨៣.៧១២ |
| សមតុល្យនៅធនាគារនានា- សុទ្ធ | ៧ | ៧៧.២៩១.៤៣៦ | ១៨.៩៦៧.២២៤ | ១០៨.១៥០.៨៦៥ | ២៦.៩១៦.៥៩២ | ៩៦.២៦៨.២៦៨ | ២៣.៨៤៦.៤៨៧ |
| ឥណទានផ្តល់ដល់អតិថិជន - សុទ្ធ | ៨ | ៣.១០៤.៧៨៧.១៦៥ | ៧៦១.៩១០.៩៦១ | ១.៩១៤.០០៩.៩៨២ | ៤៧៦.៣៥៨.៨៨១ | ១.២៧៩.៨១៤.៣៥៥ | ៣១៧.០២១.១៤៣ |
| ការវិនិយោគ | | ៦១.១២៥ | ១៥.០០០ | ៦០.២៧០ | ១៥.០០០ | ៦០.៥៥៥ | ១៥.០០០ |
| ទ្រព្យសកម្មផ្សេងៗ | | ១៥.៣៣១.៦០០ | ៣.៧៦២.៣៥៥ | ១៨.១៣៤.១៧៩ | ៤.៥១៣.២៣៥ | ៤.៦១៧.៤៥៦ | ១.១៤៣.៧៨៤ |
| ទ្រព្យ និងបរិក្ខារ | ៩ | ៧.៨៤១.២៥១ | ១.៩២៤.២៣៣ | ៦.៥៤៤.៥៤០ | ១.៦២៨.៨០៥ | ៧.៥០០.០៩៧ | ១.៨៥៧.៨៣៩ |
| ទ្រព្យសកម្មអរូបី | ១០ | ៥.១០០.២២៥ | ១.២៥១.៥៨៩ | ៤.៥០៥.៨០៩ | ១.១២១.៤០៦ | ៣.៣៨៩.៧៦៥ | ៨៣៩.៦៧៤ |
| សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម | ១១ | ១៩.៦៦៧.៥០៩ | ៤.៨២៦.៣៨៣ | ១៨.៣៨៤.៩៤១ | ៤.៥៧៥.៦៤៥ | ១៨.៤៧៣.២៣៥ | ៤.៥៧៥.៩៨១ |
| ពន្ធពន្យារជាទ្រព្យសកម្ម - សុទ្ធ | ១២(គ) | ៩.១២៧.២៦១ | ២.២៣៩.៨១៩ | ៧.៥៨១.៨៩៤ | ១.៨៨៦.៩៨២ | ៤.៤០៤.៣៧៨ | ១.០៩១.០០៣ |
| **សរុបទ្រព្យសកម្ម** | | ៤.១០២.៤១២.៦១៤ | ១.០០៦.៧២៧.០២៣ | ២.៤៤៣.៩១៤.៦១៩ | ៦០៨.២៤១.៥៦៨ | ១.៤៩៤.៨៣៣.៧១១ | ៣៧០.២៨៣.៣០៧ |

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

| | កំណត់សម្គាល់ | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | | នាថ្ងៃទី១ ខែមករា ឆ្នាំ២០១៨ | |
|---|---|---|---|---|---|---|---|
| | | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៤) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៤) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៤) |
| **បំណុលនិងមូលធន** | | | | | | | |
| **បំណុល** | | | | | | | |
| ប្រាក់បញ្ញើរបស់អតិថិជន | ១៣ | ១.៨៦៤.៩៧០.៤៩២ | ៤៥៧.៦៦១.៤៧០ | ៩៥១.៩០៥.៩២៦ | ២៣៦.៩១០.៣៨៥ | ៣៧០.៧៣៦.៥៩៧ | ៩១.៨៣៤.៦៧៨ |
| សំវិធានធនលើអត្ថប្រយោជន៍និយោជិត | ១៤ | ២.៨៥០.៦៧២ | ៦៩៩.៥៥២ | ៤.៣២៣.៧៤០ | ១.០៧៦.០៩៣ | - | - |
| បំណុលផ្សេងៗ | | ៣០.៨៩៤.២៧០ | ៧.៥៨១.៤១៦ | ៣៥.៦០៧.៨៦៦ | ៨.៨៦២.០៨៧ | ២១.៧០៥.៧៨០ | ៥.៣៧៦.៧១០ |
| ប្រាក់កម្ចី | ១៥ | ១.៥៤៧.០៤៧.១៧៧ | ៣៧៩.៦៤៣.៤៧៩ | ១.០៩៦.៩០៣.២០០ | ២៧២.៩៩៧.៣១២ | ៨៣៣.០១៧.៧៩២ | ២០៦.៣៤៥.៧៥០ |
| មូលបត្របំណុល | ១៦ | ៨១.៧១៤.៣៧៤ | ២០.០៥២.៦០៧ | - | - | - | - |
| បំណុលពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ | ១២(ខ) | ១៣.៦២១.១៨៧ | ៣.៣៤២.៦២៣ | ២០.៥២៣.៩៣៣ | ៥.១០៧.៩៩៧ | ១៣.៨៣៦.៨៣៦ | ៣.៤២៧.៥០៥ |
| បំណុលភតិសន្យា | ១៧ | ១៨.៦០២.០៣១ | ៤.៥៦៤.៩១៦ | ១៦.៨៩១.១៩៤ | ៤.២០៣.៨៨១ | ១៦.៤១៨.៤០២ | ៤.០៦៦.៩៨១ |
| **សរុបបំណុល** | | ៣.៥៥៩.៧០០.២០៣ | ៨៧៣.៥៤៦.០៦៣ | ២.១២៦.១៥៥.៨៥៩ | ៥២៩.១៥៧.៧៥៥ | ១.២៥៥.៧១៥.៤០៧ | ៣១១.០៥១.៦២៤ |

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)

## នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

| | សម្គាល់ | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | | នាថ្ងៃទី១ ខែមករា ឆ្នាំ២០១៨ | |
|---|---|---|---|---|---|---|---|
| | សម្គាល់ | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៤) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៤) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៤) |
| **មូលធន** | | | | | | | |
| ដើមទុន | ១៨ | ២២៤.៣៧៧.៤០០ | ៥៥.៤៤៤.៧៤៦ | ១២០.០០០.០០០ | ២៩.៧០៤.៣២៧ | ៧១.៦៨៤.១០០ | ១៧.៧៥៦.៧៧៥ |
| ដើមទុនបន្ថែម | | - | - | ២០.៨៤៦.៦០០ | ៥.១៥៤.៩៤៦ | - | - |
| ទុនបម្រុងទូទៅ | ១៩(ក) | ២១០.៤១៥.១១៦ | ៥១.៩៦៧.៤២៦ | ១១០.៤១៥.១១៦ | ២៧.៣០៦.៥១៤ | ៧.១៦៨.៤១០ | ១.៧៧៥.៦៧៧ |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | ១៩(ខ) | ១០.៦៩៤.៧៥៩ | ២.៦៤៥.០៣៦ | ៨.៣៨៤.៧៦៩ | ២.០៧៥.៣៧១ | ៤.៦៣២.២៤៤ | ១.១៤៧.៤៤៧ |
| ប្រាក់ចំណេញរក្សាទុក | | ៩៧.២២៥.១៣៦ | ២៤.០៨២.៣១៧ | ៥៨.១១២.២៧៥ | ១៤.៤៣៦.៧៣០ | ១៥៥.៦៣៣.៥៥០ | ៣៨.៥៥១.៧៨៤ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (៩៥៨.៥៦៥) | - | ៤០៥.៩២៥ | - | - |
| **សរុបមូលធន** | | ៥៤២.៧១២.៤១១ | ១៣៣.១៨០.៩៦០ | ៣១៧.៧៥៨.៧៦០ | ៧៩.០៨៣.៨១៣ | ២៣៩.១១៨.៣០៤ | ៥៩.២៣១.៦៨៣ |
| **សរុបបំណុលនិងមូលធន** | | ៤.១០២.៤១២.៦១៤ | ១.០០៦.៧២៧.០២៣ | ២.៤៤៣.៩១៤.៦១៩ | ៦០៨.២៤១.៥៦៨ | ១.៩៩៤.៨៣៣.៧១១ | ៣៧០.២៨៣.៣០៧ |

កំណត់សម្គាល់ ដូចមានភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល

## សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ និង១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

| | | ដំណាច់ការិយបរិច្ឆេទ ៣ខែ គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៩ | | ដំណាច់ការិយបរិច្ឆេទ ៣ខែ គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៨ (មិនបានពិនិត្យ) | | ដំណាច់ការិយបរិច្ឆេទ ១២ខែ គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៩ | | ដំណាច់ការិយបរិច្ឆេទ ១២ខែ គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៨ | |
|---|---|---|---|---|---|---|---|---|---|
| | កំណត់សម្គាល់ | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៤) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៤) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៤) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៤) |
| ចំណូលពីការប្រាក់ | ២០ | ១៤៩.៥៩៥.៦៩៦ | ៣៦.៨៩១.៦៦៤ | ៨៣.១៨៧.១១០ | ២០.៥៧០.៥០២ | ៤៧១.៩៩៣.០៧៨ | ១១៦.២៧៤.៩៩៥ | ៣១៤.៨៥៥.២៥៦ | ៧៧.៨៥៧.៣៨៣ |
| ចំណាយលើការប្រាក់ | ២០ | (៦៧.៣៤០.៩៨៥) | (១៦.៦០៦.៩០១) | (៤០.០០០.០៩៥) | (៩.៨៩១.២២០) | (២១៥.៩៨៥.៨០០) | (៥៣.១៤០.៧៦៤) | (១៣៨.៥៦២.៤៨២) | (៣៤.២៦៣.៧២០) |
| **ចំណូលពីការប្រាក់សុទ្ធ** | | ៨២.២៥៤.៧១១ | ២០.២៨៤.៧៦៣ | ៤៣.១៨៧.០១៥ | ១០.៦៧៩.២៨២ | ២៥៦.០០៧.២៧៨ | ៦៣.១៣៣.៧៣១ | ១៧៦.២៩២.៧៧៤ | ៤៣.៥៩៣.៦៦៣ |
| សំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ | ៨ | (៥.៦៣៩.៥០៨) | (១.៣៩០.៧៥៤) | (៤.២២២.៩៧៩) | (១.០៤៤.២៥៨) | (១៩.៨៧៥.៤៨៤) | (៤.៩០១.៤៧៦) | (១៦.០៦៦.៥៩២) | (៣.៩៧២.៩៤៦) |
| សំវិធានលើសមតុល្យធនាគារនានា | | ២៥៣.៨២៥ | ៦២.៥៩៦ | (១.០៩២.៤៣៣) | (២៧០.១៣៧) | ៣២៨.៨៨៥ | ៨១.១០៦ | (១.០៩២.៤៣៣) | (២៧០.១៣៧) |
| **ចំណូលពីប្រតិបត្តិការផ្សេងៗ** | | ៧៦.៨៦៩.០២៨ | ១៨.៩៥៦.៦០៥ | ៣៧.៨៧១.៦០៣ | ៩.៣៦៤.៨៨៧ | ២៣៦.៤៦០.៦៧៩ | ៥៨.៣១៣.៣៦១ | ១៥៩.១៣៣.៧៤៩ | ៣៩.៣៥០.៥៨០ |

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗសង្ខេបចន្លោះពេល (ត)

## សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ និង១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

| | កំណត់សម្គាល់ | ដំណាច់ការិយបរិច្ឆេទ ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | | ដំណាច់ការិយបរិច្ឆេទ ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ (មិនបានពិនិត្យ) | | ដំណាច់ការិយបរិច្ឆេទ ១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | | ដំណាច់ការិយបរិច្ឆេទ ១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | |
|---|---|---|---|---|---|---|---|---|---|
| | | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៤) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៤) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៤) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៤) |
| **ចំណេញពីប្រតិបត្តិការផ្សេងៗ** | | ៧៦.៨៦៩.០២៨ | ១៨.៩៥៦.៦០៥ | ៣៧.៨៧១.៦០៣ | ៩.៣៦៤.៨៨៧ | ២៣៦.៤៦០.៦៧៩ | ៥៨.៣១៣.៣៦១ | ១៥៩.១៣៣.៧៤៩ | ៣៩.៣៥០.៥៨០ |
| ចំណូលពីប្រតិបត្តិការ | | ៥.២៩៥.៧៧៥ | ១.៣០៥.៩៨៦ | ១៣.១១៦.០២៧ | ៣.២៤៣.៣៣០ | ៧០.៧៣៦.៨៩៨ | ១៧.៤៤៤.៣៦៤ | ៤០.៦៣០.៧៦២ | ១០.០៤៧.១៧២ |
| ចំណាយលើកម្រៃសេវា | | (៨៦៣.៦៧៤) | (២១២.៩៩០) | (៦៥៣.៤៥២) | (១៦១.៥៨៦) | (៣.៥៤៣.៧៦៨) | (៨៧៣.៩២៦) | (២.៣៩៨.៤៧៥) | (៥៩៣.០៩៥) |
| ចំណាយលើបុគ្គលិក | ២១ | (២៨.៥៣០.៨៩២) | (៧.០៣៥.៩៧៨) | (២២.៤៣៣.០៣៦) | (៥.៥៤៧.២៣៩) | (១០០.០៦០.៧១៩) | (២៤.៦៧៥.៨៨៦) | (៧៦.០៣៥.៣៨៩) | (១៨.៨០២.០២៥) |
| ចំណាយលើរំលស់ | | (២.៧៥៦.១៦០) | (៦៧៩.៦៩៤) | (២.៣៩៧.២៧១) | (៥៩២.៧៩៧) | (១០.៣០៧.០៨៣) | (២.៥៤១.៨២០) | (៩.០៣៤.៤៦៨) | (២.២៣៤.០៤៣) |
| ចំណាយទូទៅ និងរដ្ឋបាល | ២២ | (១០.៤២១.៧៨៧) | (២.៥៧០.១០៨) | (១១.៦៩៧.៨៥១) | (២.៨៩២.៦៤៤) | (៣៦.១៦៦.៧៤២) | (៨.៩១៩.០៤៩) | (៣៣.៤៤៤.៨៤៣) | (៨.២៧០.២៣៨) |
| ចំណេញសុទ្ធលើអាត្រាប្តូរប្រាក់ | | ១៩៣.៥៨៤ | ៤៧.៧៤០ | (៩៩២.៧១៦) | (២៣៣.១១៥) | ១.៥៦៩.៦៥៨ | ៣៨៧.០៩១ | (៣០៩.៥៥៨) | (៧៦.៥៤៧) |
| **ប្រាក់ចំណេញមុនដកពន្ធ** | | ៣៩.៧៨៥.៨៧៤ | ៩.៨១១.៥៦១ | ១២.៨៦៣.៣០៤ | ៣.១៨០.៨៣៦ | ១៥៨.៦៨៨.៩២៣ | ៣៩.១៣៤.១៣៥ | ៧៨.៥៤១.៧៧៨ | ១៩.៤២១.៨០៤ |
| ចំណាយពន្ធលើប្រាក់ចំណេញ | ១២(ឃ) | ៩.៤៧៧.២៥០ | ២.៣៣៧.១៧៦ | (៤.៣០១.៦១៥) | (១.០៦៣.៧០៣) | (១៧.២៦៦.០៧២) | (៤.២៥៧.៩៧១) | (២០.៧៤៧.៩២២) | (៥.១៣០.៥៤៥) |
| **ប្រាក់ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ** | | ៤៩.២៦៣.១២៤ | ១២.១៤៨.៧៣៧ | ៨.៥៦១.៦៨៩ | ២.១១៧.១៣៣ | ១៤១.៤២២.៨៥១ | ៣៤.៨៧៦.១៦៤ | ៥៧.៧៩៣.៨៥៦ | ១៤.២៩១.២៥៩ |
| *ចំណេញ/(ការបាត់បង់)លម្អិតផ្សេងទៀតៈ* | | | | | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | ៥៩៦.៥៧៣ | - | ១.១៦៦.២០៩ | - | (៩៥៨.៥៦៥) | - | ៤០៥.៩២៥ |
| **លទ្ធផលសរុបក្នុងការិយបរិច្ឆេទ** | | ៤៩.២៦៣.១២៤ | ១២.៧៤៥.៣១០ | ៨.៥៦១.៦៨៩ | ៣.២៨៣.៣៤២ | ១៤១.៤២២.៨៥១ | ៣៣.៩១៧.៥៩៩ | ៥៧.៧៩៣.៨៥៦ | ១៤.៦៩៧.១៨៤ |

កំណត់សម្គាល់ ដូចមានភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## របាយការណ៍ស្តីពីបម្រែបម្រួលមូលធនសង្ខេបចន្លោះពេល
## សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ និង១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

| | ដើមទុន | | ដើមទុនបន្ថែម | | ទុនបម្រុងទូទៅ | | ទុនបម្រុងតាមបទប្បញ្ញត្តិ | | ប្រាក់ចំណេញរក្សាទុក | | លម្អៀងពីការប្តូររូបិយប័ណ្ណ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៤) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៤) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៤) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៤) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៤) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៤) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៤) |
| **សមតុល្យនាថ្ងៃទី១ខែមករាឆ្នាំ២០១៨** | ៧១.៦៨៤.១០០ | ១៧.៧៥៦.៧៧៥ | - | - | ៧.១៦៨.៤១០ | ១.៧៧៥.៦៧៧ | ៤.៦៣២.២៤៤ | ១.១៤៧.៤៤៧ | ១៥៥.៦៣៣.៥៥០ | ៣៨.៥៥៩.៧៨៤ | - | - | ២៣៩.១១៨.៣០៤ | ៥៩.២៣៩.៦៨៣ |
| ការបន្ថែមដើមទុន | - | - | ២០.៨៩៦.៦០០ | ៥.១៥៤.៩៤៦ | - | - | - | - | - | - | - | - | ២០.៨៩៦.៦០០ | ៥.១៥៤.៩៤៦ |
| ការផ្ទេរប្រាក់ចំណេញរក្សាទុកទៅដើមទុន | ៤៨.៣១៥.៩០០ | ១១.៩៤៧.៥៥២ | - | - | - | - | - | - | (៤៨.៣១៥.៩០០) | (១១.៩៤៧.៥៥២) | - | - | - | - |
| ការផ្ទេរប្រាក់ចំណេញរក្សាទុកទៅទុនបម្រុងទូទៅ | - | - | - | - | ១០៣.៧៤៦.៧០៦ | ២៥.៥៣០.៨៣៧ | | | (១០៣.៧៤៦.៧០៦) | (២៥.៥៣០.៨៣៧) | - | - | - | - |
| ការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | - | - | - | - | ៣.៧៥២.៥២៥ | ៩២៧.៩២៤ | (៣.៧៥២.៥២៥) | (៩២៧.៩២៤) | - | - | - | - |
| *ចំណូលលម្អិតសរុប* | | | | | | | | | | | | | | |
| ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ | - | - | - | - | - | - | - | - | ៥៧.៧៤៣.៨៥៦ | ១៤.២៩១.២៥៩ | - | - | ៥៧.៧៤៣.៨៥៦ | ១៤.២៩១.២៥៩ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | - | - | - | ៤០៥.៩២៥ | - | ៤០៥.៩២៥ |
| | - | - | - | - | - | - | - | - | ៥៧.៧៤៣.៨៥៦ | ១៤.២៩១.២៥៩ | - | ៤០៥.៩២៥ | ៥៧.៧៤៣.៨៥៦ | ១៤.៦៩៧.១៨៤ |
| **សមតុល្យនាថ្ងៃទី៣១ខែធ្នូ ឆ្នាំ២០១៨** | ១២០.០០០.០០០ | ២៩.៧០៤.៣២៧ | ២០.៨៩៦.៦០០ | ៥.១៥៤.៩៤៦ | ១១០.៩១៥.១១៦ | ២៧.៣០៦.៥១៤ | ៨.៣៨៤.៧៦៩ | ២.០៧៥.៣៧១ | ៥៨.១១២.២៧៥ | ១៤.៤៣៦.៧៣០ | | ៤០៥.៩២៥ | ៣១៧.៧៥៨.៧៦០ | ៧៩.០៨៣.៨១៣ |
| **សមតុល្យនាថ្ងៃទី១ខែមករាឆ្នាំ២០១៩** | ១២០.០០០.០០០ | ២៩.៧០៤.៣២៧ | ២០.៨៩៦.៦០០ | ៥.១៥៤.៩៤៦ | ១១០.៩១៥.១១៦ | ២៧.៣០៦.៥១៤ | ៨.៣៨៤.៧៦៩ | ២.០៧៥.៣៧១ | ៥៨.១១២.២៧៥ | ១៤.៤៣៦.៧៣០ | - | ៤០៥.៩២៥ | ៣១៧.៧៥៨.៧៦០ | ៧៩.០៨៣.៨១៣ |
| ការផ្ទេរដើមទុនបន្ថែមទៅជាដើមទុន | ២០.៨៩៦.៦០០ | ៥.១៨០.៩៦២ | (២០.៨៩៦.៦០០) | (៥.១៥៤.៩៤៦) | - | - | - | - | - | - | - | ១៣.៩៨៤ | - | - |
| ការបន្ថែមដើមទុន | ៨៣.៥៣០.៨០០ | ២០.៥៩៩.៤៥៧ | - | - | - | - | - | - | - | - | - | - | ៨៣.៥៣០.៨០០ | ២០.៥៩៩.៤៥៧ |
| ការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | - | - | - | - | ២.៣០៩.៩៩០ | ៥៦៩.៦៦៥ | (២.៣០៩.៩៩០) | (៥៦៩.៦៦៥) | - | - | - | - |
| ការផ្ទេរទៅទុនបម្រុង | | | | | ១០០.០០០.០០០ | ២៤.៦៦០.៩១២ | | | (១០០.០០០.០០០) | (២៤.៦៦០.៩១២) | - | - | - | - |
| *ចំណូលលម្អិតផ្សេងៗ* | - | - | - | - | - | - | - | - | | | - | - | | |
| ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ | - | - | - | - | - | - | - | - | ១៤១.៧២២.៨៥១ | ៣៤.៨៧៦.១៦៤ | - | - | ១៤១.៧២២.៨៥១ | ៣៤.៨៧៦.១៦៤ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | | | - | (១.៣៧៨.៤៧៤) | - | (១.៣៧៨.៤៧៤) |
| | - | - | - | - | - | - | - | - | ១៤១.៧២២.៨៥១ | ៣៤.៨៧៦.១៦៤ | - | (១.៣៧៨.៤៧៤) | ១៤១.៧២២.៨៥១ | ៣៣.៤៩៧.៦៩០ |
| **សមតុល្យនាថ្ងៃទី៣១ខែធ្នូ ឆ្នាំ២០១៩** | ២២៤.៤២៧.៤០០ | ៥៥.៤៨៤.៧៤៦ | - | - | ២១០.៩១៥.១១៦ | ៥១.៩៦៧.៤២៦ | ១០.៦៩៤.៧៥៩ | ២.៦៤៥.០៣៦ | ៩៧.៥២៥.១៣៦ | ២៤.០៨២.៣១៧ | - | (៩៥៨.៥៦៥) | ៥៤៣.០១២.៤១១ | ១៣៣.១៨០.៩៦០ |

កំណត់សម្គាល់ ដូចមានភ្ជាប់មកជាមួយគឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## របាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល
## សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ និង១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

| | ដំណាច់ការិយបរិច្ឆេទ ១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | | ដំណាច់ការិយបរិច្ឆេទ ១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៤) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៤) |
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | |
| ប្រាក់ចំណេញសុទ្ធក្នុងការិយបរិច្ឆេទ | ១៤១.៤២២.៨៥១ | ៣៤.៨៧៦.១៦៤ | ៥៧.៧៩៣.៨៥៦ | ១៤.២៩១.២៥៩ |
| *និយ័តភាពលើ៖* | | | | |
| ចំណូលការប្រាក់សុទ្ធ | (២៥៦.០០៧.២៧៨) | (៦៣.១៣៣.៧៣១) | (១៧៦.២៩២.៧៧៤) | (៤៣.៥៩៣.៦៦៣) |
| រំលស់លើទ្រព្យ និងបរិក្ខារ | ៤.៣៨១.៥៥៥ | ១.០៨០.៥៣១ | ៣.៩៤៣.១៦៩ | ៩៧៥.០៦៧ |
| រំលស់លើទ្រព្យសកម្មអរូបី | ៣៩៤.០៦២ | ៩៧.១៧៩ | ២២៦.១៩៤ | ៥៥.៩៣៣ |
| រំលស់លើសិទ្ធិប្រើទ្រព្យសកម្ម | ៥.៥៣១.៤៦៦ | ១.៣៦៤.១១០ | ៤.៨៦៥.១០៥ | ១.២០៣.០៤៣ |
| ចំណាយពន្ធលើប្រាក់ចំណេញ | ១៧.២៦៦.០៧២ | ៤.២៥៧.៩៧១ | ២០.៧៤៧.៩២២ | ៥.១៣០.៥៤៥ |
| សំវិធានធនលើប្រាក់អតីតភាពការងារ | (១.៤៧៣.០៦៨) | (៣៦៣.២៧២) | ៤.៣២៣.៧៤០ | ១.០៦៩.១៧៤ |
| ចំណេញពីការលក់ទ្រព្យ និងបរិក្ខារ | (១៥.០៧២) | (៣.៧១៦) | (១៥៦.៥៥៣) | (៣៨.៧១១) |
| សំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យ | ១៩.៨៧៥.៤៨៤ | ៤.៩០១.៤៧៦ | ១៦.០៦៦.៥៩២ | ៣.៩៧២.៩៤៦ |
| សំវិធានធនលើប្រាក់តម្កល់នៅធនាគារនានា | (៣២៨.៨៨៥) | (៨១.១០៦) | ១.០៩២.៤៣៣ | ២៧០.១៣៧ |
| | (៦៨.៩៥២.៨១៣) | (១៧.០០៤.៣៩៤) | (៦៧.៣៩០.៣១៦) | (១៦.៦៦៤.២៧០) |
| បម្រែបម្រួលនៃ៖ | | | | |
| ឥណទានផ្តល់ជូនអតិថិជន | (១.២០១.៩៦០.០២៧) | (២៩៦.៤១៤.៣១០) | (៦៤៤.៨៣៦.០២១) | (១៥៩.៤៥៥.០០០) |
| ប្រាក់បម្រុងកាតព្វកិច្ច | (៧០.៤១៣.៦៦៧) | (១៧.៣៦៤.៦៥៣) | (៥៧.៥៣៦.១២១) | (១៤.២២៧.៥២៧) |
| ទ្រព្យសកម្មផ្សេងៗ | ២.៨០១.៧២៤ | ៦៩០.៩៣១ | (១៣.៥១៦.៤៣៨) | (៣.៣៤២.៣៤៤) |
| ប្រាក់បញ្ញើរបស់អតិថិជន | ៨៩២.៥៨២.៥៩០ | ២២០.១១៩.០១១ | ៥៧០.៤៨៥.០៣៩ | ១៤១.០៦៩.៤៩៥ |
| បំណុលផ្សេងៗ | (៤.៧១៣.៥៩៦) | (១.១៦២.៤១៥) | ១៣.៩០២.០៨៦ | ៣.៤៣៧.៧០៧ |
| **សាច់ប្រាក់ប្រើក្នុងប្រតិបត្តិការ** | (៤៥០.៦៥៥.៧៨៩) | (១១១.១៣៥.៨៣០) | (១៩៨.៨៩១.៧៧១) | (៤៩.១៨១.៩៣៩) |
| ការប្រាក់បានទទួល | ៤៦១.០២៧.៦៤៣ | ១១៣.៦៩៣.៦២២ | ៣១៥.៤២១.៥០៤ | ៧៧.៩៩៧.៤០៤ |
| ការប្រាក់បានបង់ | (១៩០.៤២៥.៦៧៤) | (៤៦.៩៦០.៧០៩) | (១២៦.៥៧០.១១៥) | (៣១.២៩៨.២៤៨) |
| ពន្ធលើប្រាក់ចំណេញបានបង់ | (២៥.៧១៤.១៨៥) | (៦.៣៤១.៣៥៣) | (១៧.២៣៨.៣៤១) | (៤.២៦២.៦៩៦) |
| **សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពប្រតិបត្តិការ** | (២០៥.៧៦៨.០០៥) | (៥០.៧៤៤.២៧០) | (២៧.២៧៨.៧២៣) | (៦.៧៤៥.៤៧៩) |

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## របាយការណ៍លំហូរទឹកប្រាក់សង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ និង១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

| | ដំណាច់ការិយបរិច្ឆេទ ១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | | ដំណាច់ការិយបរិច្ឆេទ ១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៤) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៤) |
| **លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ** | | | | |
| ប្រាក់បញ្ញើមានកាលកំណត់លើសពី៣ខែ | - | - | ៤.៨៤៤.៤០០ | ១.១៩៧.៩២៣ |
| ប្រាក់តម្កល់ធានាលើដើមទុន | (១០.៤៣៧.៧៤០) | (២.៥៧៤.០៤២) | (៤.៨៣១.៥៩០) | (១.១៩៤.៧៥៥) |
| សាច់ប្រាក់ទទួលបានពីការលក់ទ្រព្យ និងបរិក្ខារ | ១៦.១៣៥ | ៣.៩៧៩ | ១៦៥.៩៩១ | ៤១.០៤៦ |
| ការទិញទ្រព្យ និងបរិក្ខារ | (៥.៦៨៥..៦១៧) | (១.៤០២.១២៥) | (២.៩៩៧.០៤៩) | (៧៤១.១១០) |
| ការទិញទ្រព្យសកម្មអរូបី | (៩៨៨.៤៧៨) | (២៤៣.៧៦៨) | (១.៣៩២.២៣៨) | (៣៣១.៩០៩) |
| **សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពវិនិយោគ** | (១៧.០៩៥.៧០០) | (៤.២១៥.៩៥៦) | (៤.១៦០.៤៨៦) | (១.០២៨.៨០៥) |
| **លំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | ៧៣៧.៥៦១.៥៣១ | ១៨១.៨៨៩.៤០៣ | ៥៩០.៥៨៥.២៤១ | ១៤៦.០៣៩.៨៧២ |
| ការទូទាត់ប្រាក់កម្ចី | (២៩០.៤៩៤.៥៩០) | (៧១.៥៧៦.០៥២) | (៣៣២.១៣៦.៧១៣) | (៨២.១៣០.៧៤០) |
| សាច់ប្រាក់ទទួលបានពីទុនបន្ថែម | ៤១.៧៦៥.៤០០ | ១០.២៩៩.៧២៩ | - | - |
| សាច់ប្រាក់ពីការលក់មូលបត្របំណុល | ៨០.៥៣១.៣៥១ | ១៩.៨៥៩.៧៦៦ | - | - |
| ដើមទុនបន្ថែម | ៤១.៧៦៥.៤០០ | ១០.២៩៩.៧២៩ | ២០.៨៤៦.៦០០ | ៥.១៥៤.៩៤៦ |
| ការទូទាត់បំណុលភតិសន្យា | (៥.៦២៤.៨៧១) | (១.៣៨៧.១៩៤) | (៤.៨៧១.៣៨៤) | (១.២០៤.៥៩៥) |
| **សាច់ប្រាក់សុទ្ធទទួលបានពី សកម្មភាពហិរញ្ញប្បទាន** | ៦០៥.៧៥៧.៩២១ | ១៤៩.៣៨៥.៤៣១ | ២៧៤.៤២៣.៧៤៤ | ៦៧.៨៥៩.៤៨៣ |
| ការកើនឡើងសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល | ៣៨២.៨៩៤.២១៦ | ៩៤.៤២៥.២០៥ | ២៤២.៩៨៤.៥៣៦ | ៦០.០៨៥.១៩៩ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាដើមការិយបរិច្ឆេទ | ៣៦៩.៥៣៧.០៥០ | ៩១,៩៧០,៣៩៦ | ១២៦.៥៥២.៥១៤ | ៣១.២៩៣.៨៩៦ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | (១,៧៤៩,៨៩២) | - | ៥៩១.៣០១ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាចុងការិយបរិច្ឆេទ (កំណត់សម្គាល់ ២៣)** | ៧៥២.៤៣១.២៦៦ | ១៨៤.៦៤៥.៧០៩ | ៣៦៩.៥៣៧.០៥០ | ៩១.៩៧០.៣៩៦ |

កំណត់សម្គាល់ ដែលបានភ្ជាប់មកជាមួយគឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល
## សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ និង១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

## ១. អំពីក្រុមហ៊ុន

**អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី** (ពីមុនជាធនាគារភូមិ) ហៅកាត់ថា ("ក្រុមហ៊ុន") ជាក្រុមហ៊ុន ដែលមានអាជ្ញាប័ណ្ណជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពីធនាគារជាតិនៃកម្ពុជា នាថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០២ និងធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥ ហើយបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មជាក្រុមហ៊ុនសាធារណជនទទួលខុសត្រូវមានកម្រិត ក្រោមបញ្ជីពាណិជ្ជកម្មលេខ Co. ១៥១៣ E/២០០២ ហើយបានប្តូរលេខចុះបញ្ជីទៅលេខ ០០០១២៨២៩ ។ ក្រោយពីមានការផ្លាស់ប្តូររចនាសម្ព័ន្ធភាគហ៊ុន នៅក្នុងខែកញ្ញា ឆ្នាំ២០១៤ ក្រុមហ៊ុនបានក្លាយជាបុត្រសម្ព័ន្ធ របស់ក្រុមហ៊ុន LOLC Micro Investments Ltd ដែល បានចុះបញ្ជីនៅប្រទេសស្រីលង្កា។ ក្រុមហ៊ុនមេធំបំផុត គឺក្រុមហ៊ុន LOLC Holdings PLC (ពីមុនឈ្មោះថា Lanka ORIX Leasing Company PLC) ដែលបានចុះបញ្ជីនៅប្រទេសស្រីលង្កា និងបានចុះបញ្ជីនៅផ្សារហ៊ុន Colombo ។

នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៧ LOLC Micro investments Ltd. និង DWM Investment Asia Ltd បានផ្ទេរ/លក់ភាគទុនទាំងអស់ ៩៦.៩៧% ទៅ LOLC Private Limited ។ ការផ្ទេរនេះ ត្រូវបានអនុម័តដោយធនាគារជាតិនៃកម្ពុជានៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៧ ។ បន្ថែមទៀត ភាគទុនត្រូវបានអនុម័តក្នុងការប្តូរកម្មសិទ្ធិករដោយធនាគារជាតិនៃ កម្ពុជាថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨ និងទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ ។

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺផ្តល់សេវាហិរញ្ញវត្ថុ (ទទួលប្រាក់បញ្ញើសន្សំ និងកម្ចី) ទៅប្រជាជននៅតាមជនបទ និងសហគ្រាសខ្នាតតូច និងសហគ្រាសខ្នាតមធ្យម តាមរយៈការិយាល័យកណ្តាលនៅភ្នំពេញ និងសាខាដទៃទៀតក្នុងព្រះរាជាណាចក្រកម្ពុជា ។ គោលបំណងចម្បងរបស់ក្រុមហ៊ុនគឺផ្តល់នូវសេវាហិរញ្ញវត្ថុ ដែលអាចជឿទុកចិត្តបាន និងមានតម្លៃសមរម្យដល់សហគ្រាសខ្នាតតូច និងសហគ្រាសខ្នាតមធ្យម ។

នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៥ ក្រុមហ៊ុនទទួលបានអាជ្ញាប័ណ្ណសម្រាប់ការទទួលប្រាក់បញ្ញើពីសាធារណជន ដើម្បីធ្វើអាជីវកម្មទទួលប្រាក់បញ្ញើ ពីធនាគារជាតិនៃកម្ពុជា ។

ក្រុមហ៊ុនមាន ៧៩ ការិយាល័យ (សាខាចំនួន ៧៨ ការិយាល័យ និងទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ) ។ ទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុនមានទីតាំងស្ថិតនៅអាគារលេខ ៦៦៦B ផ្លូវលេខ ២៧១ សង្កាត់បឹងទំពុនទី២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ក្រុមហ៊ុនមានបុគ្គលិកចំនួន ២.៧៥៧ នាក់ (៣១ ខែធ្នូ ឆ្នាំ ២០១៨: ២.៣២៧ នាក់) ។

## អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

### កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
### សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ និង១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

## ២. មូលដ្ឋាននៃការរៀបចំ

### (ក) របាយការណ៍អនុលោមភាព

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា ៣៤ "របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល" ។ នេះគឺជារបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេលលើកដំបូងរបស់សម្រាប់ផ្នែកនៃការិយបរិច្ឆេទ ដែលគ្របដណ្តប់ដោយរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ដែលនឹង អនុវត្តតាមស្តង់ដាររបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ។ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ១ "ការអនុវត្តដំបូងនៃស្តង់ដាររបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា" ។ របាយការណ៍ហិរញ្ញវត្ថុនេះ មិនបានបញ្ចូលព័ត៌មានចាំបាច់ពេញលេញសម្រាប់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនៅឡើយ ។

ការពន្យល់អំពីផលប៉ះពាល់នៃការផ្លាស់ប្តូរ ទៅស្តង់ដាររបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា "ស.រ.ទ.ហ.អ.ក" លើស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ក្រុមហ៊ុន ត្រូវបានបកស្រាយនៅក្នុងកំណត់សម្គាល់ ២៦ ។ កំណត់សម្គាល់ នេះរួមបញ្ចូលចំនួនការផ្ទៀងផ្ទាត់នូវមូលធន និងលទ្ធផលលម្អិត សម្រាប់ការិយបរិច្ឆេទប្រៀបធៀប និងមូលធននៅកាលបរិច្ឆេទនៃការផ្លាស់ប្តូរក្រោមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍របស់ធនាគារជាតិនៃកម្ពុជាទាក់ទងនឹងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់ដំណាច់ការិយបរិច្ឆេទនៃការរៀបចំរបាយការណ៍ទាំងនោះ និងការិយបរិច្ឆេទនៃការផ្លាស់ប្តូរទៅ ស.រ.ទ.ហ.អ.ក ។

របាយការណ៍ហិរញ្ញវត្ថុនេះត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុននៅថ្ងៃទី ១៤ខែកុម្ភៈ ឆ្នាំ២០២០ ។

### (ខ) មូលដ្ឋាននៃការវាស់វែង

របាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល របស់ក្រុមហ៊ុនត្រូវបានរៀបចំឡើងទៅតាមមូលដ្ឋានតម្លៃដើម ។

### (គ) រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ

ក្រុមហ៊ុនធ្វើប្រតិបត្តិការអាជីវកម្ម និងកត់ត្រារាល់បញ្ជីគណនេយ្យរបស់ខ្លួនផ្អែកលើរូបិយប័ណ្ណចំនួនបីគឺ ប្រាក់រៀល ប្រាក់ដុល្លារអាមេរិក និងប្រាក់បាតថៃ ។ គណៈគ្រប់គ្រងបានកំណត់ប្រាក់រៀលជារូបិយប័ណ្ណមុខងារ និងជារូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ ព្រោះវាឆ្លុះបញ្ចាំងពីភាពចាំបាច់នៃសេដ្ឋកិច្ចប្រភពព្រឹត្តិការណ៍ និងកាលៈទេសៈរបស់ក្រុមហ៊ុន ។

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ និង១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

### ២. មូលដ្ឋាននៃការរៀបចំ (ត)

### (គ) រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ (ត)

សកម្មភាពប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗទៀតក្រៅពីប្រាក់រៀល ត្រូវបានប្តូរទៅជាប្រាក់រៀល ដោយប្រើអត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការនោះ ។ សមតុល្យនៃទ្រព្យសកម្មរូបិយវត្ថុ និងបំណុលរូបិយវត្ថុ នាកាលបរិច្ឆេទរាយការណ៍ ដែលជារូបិយប័ណ្ណក្រៅពីប្រាក់រៀល ក៏ត្រូវបានប្តូរទៅជាប្រាក់រៀលដោយប្រើអត្រានាកាលបរិច្ឆេទនោះ ។ ភាពលម្អៀងពីការប្តូររូបិយប័ណ្ណដែលកើតមាននោះ ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត ។

### (ឃ) ការប៉ាន់ស្មាន និងការវិនិច្ឆ័យ

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល ដែលអនុលោមទៅតាមគោលនយោបាយគណនេយ្យតម្រូវឲ្យគណៈគ្រប់គ្រងធ្វើការវិនិច្ឆ័យ ប៉ាន់ស្មាន និងសន្មត់តាមគណនេយ្យឲ្យបានច្បាស់លាស់ ដែលមានផលប៉ះពាល់ដល់ចំនួននៃទ្រព្យសកម្ម បំណុល ចំណូល និងចំណាយដែលបានរាយការណ៍ក្នុងការិយបរិច្ឆេទ។ លទ្ធផលជាក់ស្តែងអាចខុសពីការប៉ាន់ស្មានទាំងនេះ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ គណៈគ្រប់គ្រងប្រើប្រាស់ការវិនិច្ឆ័យ ដោយអនុលោមតាមគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុន ហើយប្រភពសំខាន់ៗនៃភាពមិនច្បាស់លាស់នៃការប៉ាន់ស្មានត្រូវបានរំពឹងទុកថានឹងមានភាពដូចគ្នា សម្រាប់ការអនុវត្តជាលើកដំបូងនៃរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំស្របតាម ស.រ.ទ.ហ.អ.ក ។

ការប៉ាន់ស្មាន និងការសន្មត់ត្រូវបានពិនិត្យឡើងវិញជាប្រចាំ។ ការកែប្រែទៅលើការប៉ាន់ស្មានគណនេយ្យត្រូវបានទទួលស្គាល់ និងកត់ត្រានៅក្នុងការិយបរិច្ឆេទ ដែលការប៉ាន់ស្មាននោះត្រូវបានកែប្រែ និងការិយបរិច្ឆេទអនាគតដែលមានផលប៉ះពាល់ដោយការកែប្រែនេះ ។

ផ្នែកសំខាន់ៗនៃការប៉ាន់ស្មាន ការវិនិច្ឆ័យមិនច្បាស់លាស់និងសំខាន់ៗ ដែលត្រូវបានប្រើក្នុងការអនុវត្តគោលនយោបាយគណនេយ្យ មានផលប៉ះពាល់ជាសារវន្តក្នុងការកំណត់ចំនួនដែលទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានដូចខាងក្រោម៖

- កំណត់សម្គាល់ ៣(ក)(ii)៖ ការចាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ៖ ការវាយតម្លៃគំរូអាជីវកម្មដែលទ្រព្យទាំងនោះត្រូវបានកាន់កាប់ និងការវាយតម្លៃថាតើលក្ខខណ្ឌកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុគឺជាការទូទាត់តែប្រាក់ដើមនិងការប្រាក់ ("SPPI") លើចំនួនប្រាក់ដើមដែលនៅសល់។
- កំណត់សម្គាល់ ៣(ក)(vii)៖ ការបង្កើតលក្ខណៈវិនិច្ឆ័យសម្រាប់កំណត់ថាតើហានិភ័យឥណទានលើទ្រព្យសកម្មហិរញ្ញវត្ថុបានកើនឡើងគួរឲ្យកត់កំណត់សម្គាល់ ចាប់តាំងពីការទទួលស្គាល់ដំបូង ដោយកំណត់វិធីសាស្ត្រសម្រាប់បញ្ចូលព័ត៌មានទៅក្នុងការវាស់វែងនៃការរំពឹងទុកលើការខាតបង់ឥណទាន ("ECL") និងការជ្រើសរើស និងការអនុម័តលើគំរូដែលប្រើដើម្បីវាស់ ECL ។

# អេសអេសអេសស៊ី (ខេមបូឌា) ភីអិលស៊ី

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ និង១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

## ២. មូលដ្ឋាននៃការរៀបចំ (ត)

### (ឃ) ការប៉ាន់ស្មាន និងការវិនិច្ឆ័យ (ត)

ព័ត៌មានអំពីភាពមិនច្បាស់លាស់នៃការសន្មត់ និងការប៉ាន់ស្មាន ដែលមានហានិភ័យគួរឲ្យកត់កំណត់សម្គាល់ទៅលើតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនាពេលអនាគត ត្រូវបានបញ្ចូលក្នុងកំណត់សម្គាល់ ដូចខាងក្រោម៖

- កំណត់សម្គាល់ ៣(ក)(vii)៖ ឱនភាពនៃឧបករណ៍ហិរញ្ញវត្ថុ៖ កំណត់ការបញ្ចូលសមាសធាតុទៅក្នុងគំរូនៃការវាស់វែង ការខាតបង់ឥណទានដែលរំពឹងទុក ("ECL") រួមទាំងការបញ្ចូលព័ត៌មាននាពេលអនាគត ។

- កំណត់សម្គាល់ ៣ (ក)(vii)៖ ឱនភាពនៃឧបករណ៍ហិរញ្ញវត្ថុ៖ ការសន្មតសំខាន់ៗដែលប្រើក្នុងការប៉ាន់ស្មានលំហូរទឹកប្រាក់ដែលអាចប្រមូលមកវិញបាន ។

### (ង) ការវាស់វែងតម្លៃសមស្រប

**ការវាស់វែងតម្លៃសមស្រប**

គោលនយោបាយគណនេយ្យ និងការបង្ហាញព័ត៌មានមួយចំនួនរបស់ក្រុមហ៊ុនទាមទារឲ្យមានការវាស់វែងតម្លៃសមស្រប សម្រាប់ទាំងទ្រព្យសកម្មហិរញ្ញវត្ថុ និងទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ និងបំណុល ។

ក្រុមហ៊ុនបានបង្កើតក្របខណ្ឌត្រួតពិនិត្យដោយគោរពតាមការវាស់វែងតម្លៃសមស្រប ។ ក្របខណ្ឌនេះរួមមានគណៈគ្រប់គ្រងដែលមានការទទួលខុសត្រូវចំពោះការវាស់វែងតម្លៃសមស្របទាំងអស់ រួមទាំងតម្លៃសមស្របកម្រិតទី ៣ និងរាយការណ៍ដោយផ្ទាល់ទៅគណៈគ្រប់គ្រង ។

គណៈគ្រប់គ្រងត្រួតពិនិត្យជាទៀងទាត់នូវធាតុចូលដែលមិនអាចគ្រប់គ្រងបាន និងការកែតម្រូវតម្លៃ ។ ប្រសិនបើព័ត៌មានរបស់ភាគីទីបី ដូចជាតារាងតម្លៃ ឬតម្លៃសេវារបស់ឈ្មួញកណ្តាល ត្រូវបានប្រើដើម្បីវាស់តម្លៃសមស្រប នោះគណៈគ្រប់គ្រងធ្វើការវាយតម្លៃ និងរក្សាទុកឯកសារភស្តុតាងដែលទទួលបានពីភាគីទីបី ដើម្បីគាំទ្រដល់ការសន្និដ្ឋានថាការវាយតម្លៃទាំងនេះបានបំពេញតាមតម្រូវការរបស់ ស.រ.ហ.អ.ក រួមទាំងកម្រិតនៅក្នុងឋានានុក្រមនៃតម្លៃសមស្រប ដែលការវាយតម្លៃ គួរតែត្រូវបានចាត់ថ្នាក់ ។

បញ្ហានៃការវាយតម្លៃសំខាន់ៗត្រូវបានរាយការណ៍ទៅគណៈកម្មាធិការសវនកម្មរបស់ក្រុមហ៊ុន ។

# កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
# សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ និង១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

## ២. មូលដ្ឋាននៃការរៀបចំ (ត)

### (ង) ការវាស់វែងតម្លៃសមស្រប (ត)

**ការវាស់វែងតម្លៃសមស្រប (ត)**

នៅពេលវាស់វែងតម្លៃសមស្របនៃទ្រព្យសកម្ម ឬបំណុល ក្រុមហ៊ុនត្រូវប្រើទិន្នន័យទីផ្សារដែលអាចអង្កេតបានតាមដែលអាចធ្វើទៅបាន ។ តម្លៃសមស្រប ត្រូវបានបែងចែកជាកម្រិតផ្សេងៗគ្នាតាមឋានានុក្រមនៃតម្លៃសមស្រប ដោយផ្អែកលើធាតុចូលដែលប្រើក្នុងបច្ចេកទេសវាយតម្លៃដូចខាងក្រោម៖

- កម្រិត ១ : សម្រង់តម្លៃ (មិនទាន់កែតម្រូវ) នៅក្នុងទីផ្សារជាក់ស្តែងសម្រាប់ទ្រព្យសកម្ម ឬបំណុលដូចគ្នា
- កម្រិត ២ : ធាតុចូល ដែលក្រៅពីសម្រង់តម្លៃនៅក្នុងកម្រិត ១ ដែលអាចសង្កេតបានសម្រាប់ទ្រព្យសកម្ម ឬបំណុល ទោះជាអាចទទួលបានដោយផ្ទាល់ (តម្លៃ) ឬដោយប្រយោល (ទាញយកពីតម្លៃ) ។
- កម្រិត ៣ : ធាតុចូល សម្រាប់ទ្រព្យសកម្ម ឬបំណុលដែលមិនផ្អែកលើទិន្នន័យទីផ្សារដែលអាចអង្កេតបាន (ធាតុចូលដែលមិនអាចអង្កេតបាន) ។

ប្រសិនបើធាតុចូល ដែលត្រូវបានប្រើដើម្បីវាស់វែងតម្លៃសមស្របនៃទ្រព្យសកម្ម ឬបំណុល ស្ថិតនៅក្នុងកម្រិតខុសគ្នានៃឋានានុក្រមតម្លៃសមស្រប នោះការវាស់វែងតម្លៃសមស្របត្រូវបានចាត់ថ្នាក់នៅក្នុងកម្រិតដូចគ្នានៃឋានានុក្រមតម្លៃសមស្រប ជាធាតុចូលកម្រិតទាបបំផុត ហើយមានសារៈសំខាន់ចំពោះការវាស់វែងទាំងមូល (កម្រិត ៣ គឺទាបបំផុត) ។

ក្រុមហ៊ុន ទទួលស្គាល់ការផ្ទេរប្រាក់រវាងកម្រិតនៃឋានានុក្រមតម្លៃសមស្របនាចុងការិយបរិច្ឆេទនៃរបាយការណ៍ អំឡុងពេលដែលមានការផ្លាស់ប្តូរ។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ

គោលនយោបាយគណនេយ្យសំខាន់ៗ ដែលបានប្រើប្រាស់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុក្នុងគ្រានេះ ត្រូវបានបង្ហាញខាងក្រោម ។ គោលនយោបាយគណនេយ្យទាំងនេះ ត្រូវបានអនុវត្តប្រកបដោយសង្គតិភាពគ្រប់ការិយបរិច្ឆេទទាំងអស់ដែលបានបង្ហាញ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ ។

### (ក) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

*(i) ការទទួលស្គាល់ និងការវាស់វែងជាលើកដំបូង*

ក្រុមហ៊ុនទទួលស្គាល់ជាលើកដំបូងនូវឥណទាន ប្រាក់កម្ចី និងអនុបំណុល នៅកាលបរិច្ឆេទដែលកើតមានប្រតិបត្តិការ ។ ទ្រព្យហិរញ្ញវត្ថុផ្សេងទៀត ទទួលស្គាល់នៅកាលបរិច្ឆេទ ដែលក្រុមហ៊ុនក្លាយជាភាគីកិច្ចសន្យា ។

ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្រប (សម្រាប់ឧបករណ៍ដែលមិនមែនវាស់វែងតាមតម្លៃសមស្របតាមរយៈចំណេញ ឬខាត (FVTPL)) បូកនឹងថ្លៃដើមប្រតិបត្តិការដែលកើតមកពីការទិញ ឬលក់ ទ្រព្យ និងបំណុលទាំងនោះ ។

*(ii) ការចាត់ចំណាត់ថ្នាក់*

#### ទ្រព្យសកម្មហិរញ្ញវត្ថុ

សម្រាប់ការទទួលស្គាល់ជាលើកដំបូង ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានវាស់វែងតាមៈ រំលស់ថ្លៃដើម តម្លៃសមស្របតាមរយៈលទ្ធផលលម្អិតផ្សេងៗ "FVOCI" ឬ តម្លៃសមស្របតាមរយៈចំណេញ ឬខាត ("FVTPL") ។

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម ប្រសិនបើវាត្រូវនឹងលក្ខខណ្ឌដូចខាងក្រោម ហើយមិនត្រូវបានកំណត់ជា FVTPL នោះទេៈ

- ទ្រព្យសកម្មដែលមាននៅក្នុងគំរូអាជីវកម្ម ក្នុងគោលបំណងរក្សាទុកដើម្បីការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា និង
- លក្ខខណ្ឌកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ផ្តល់នូវកាលបរិច្ឆេទជាក់លាក់ចំពោះលំហូរទឹកប្រាក់ដែលសម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់ (SPPI) ។

ឧបករណ៍បំណុលហិរញ្ញវត្ថុត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម ប្រសិនបើវាត្រូវនឹងលក្ខខណ្ឌដូចខាងក្រោម ហើយមិនត្រូវបានកំណត់ជា FVTPL នោះទេៈ

- ទ្រព្យសកម្មដែលមាននៅក្នុងគំរូអាជីវកម្ម ក្នុងគោលបំណងរក្សាទុកដើម្បីការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា និងលក់ទ្រព្យសកម្មហិរញ្ញវត្ថុ និង
- លក្ខខណ្ឌកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ផ្តល់នូវកាលបរិច្ឆេទជាក់លាក់ចំពោះលំហូរទឹកប្រាក់ដែលសម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់ (SPPI) ។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ក) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(ii) ការចាត់ចំណាត់ថ្នាក់ (ត)*

**ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)**

សម្រាប់ការទទួលស្គាល់ការវិនិយោគលើមូលធនជាលើកដំបូង ដែលមិនត្រូវបានកាន់កាប់សម្រាប់ជួញដូរ ក្រុមហ៊ុនត្រូវតែជ្រើសរើសការបង្ហាញការប្រែប្រួលនាពេលបន្ទាប់តាមរយៈលទ្ធផលលម្អិតផ្សេងៗ ។ ការជ្រើសរើសនេះធ្វើឡើងដោយផ្អែកលើការវិនិយោគនីមួយៗ ។

**ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ផ្សេងទៀតត្រូវបានចាត់ថ្នាក់តាមការវាស់វែងដោយ FVTPL**

លើសពីនេះ សម្រាប់ការទទួលស្គាល់ជាលើកដំបូង ក្រុមហ៊ុនអាចនឹងកំណត់ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបំពេញតាមលក្ខខណ្ឌក្នុងការវាស់វែងតាមរំលស់ថ្លៃដើម ឬតាម FVOCI ប្រសិនបើវាស់វែងតាម FVTPL នឹងលុបបំបាត់ ឬកាត់បន្ថយជាសារវន្តនូវភាពមិនស៊ីគ្នានៃគណនេយ្យដែលនឹងកើតឡើង ។

**ការវាយតម្លៃគំរូអាជីវកម្ម**

ក្រុមហ៊ុនធ្វើការវាយតម្លៃលើគោលបំណងនៃគំរូអាជីវកម្ម លើទ្រព្យសកម្មនៅក្នុងកម្រិតសំណុំឥណទាននីមួយៗ ព្រោះគំរូនេះបង្ហាញយ៉ាងច្បាស់ពីវិធីគ្រប់គ្រងអាជីវកម្ម និងវិធីផ្តល់ព័ត៌មានទៅគណៈគ្រប់គ្រង។ ព័ត៌មានទាំងនោះរួមមាន៖

- គោលនយោបាយ និងគោលបំណងដែលបានបញ្ជាក់សម្រាប់សំណុំឥណទាន និងអនុវត្តនូវគោលនយោបាយទាំងនោះ ។ ជាពិសេសថាតើយុទ្ធសាស្ត្ររបស់គណៈគ្រប់គ្រង ផ្តោតលើការស្វែងរកចំណូលការប្រាក់តាមកិច្ចសន្យា រក្សានូវទម្រង់អត្រាការប្រាក់ជាក់លាក់មួយ ធ្វើឲ្យស៊ីសង្វាក់គ្នារវាងរយៈពេលនៃទ្រព្យសកម្មហិរញ្ញវត្ថុ ទៅនឹងរយៈពេលនៃបំណុល ដែលជាហិរញ្ញប្បទានរបស់ទ្រព្យសកម្មទាំងនោះ ឬការធ្វើឲ្យមានលំហូរទឹកប្រាក់តាមរយៈការលក់ទ្រព្យសកម្ម ។
- វិធីក្នុងការវាយតម្លៃលទ្ធផលនៃសំណុំឥណទាន និងវិធីរាយការណ៍ទៅគណៈគ្រប់គ្រងរបស់ក្រុមហ៊ុន។
- ហានិភ័យដែលប៉ះពាល់ដល់លទ្ធផលនៃគំរូអាជីវកម្ម (និងទ្រព្យសកម្មហិរញ្ញវត្ថុដែលមាននៅក្នុងគំរូអាជីវកម្មនោះ) និងយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងហានិភ័យទាំងនោះ ។
- របៀបដែលអ្នកគ្រប់គ្រងអាជីវកម្មទទួលបានការទូទាត់ (ឧទាហរណ៍៖ តើការទូទាត់ផ្អែកលើតម្លៃសមស្របនៃទ្រព្យសកម្មដែលបានគ្រប់គ្រង ឬសាច់ប្រាក់តាមកិច្ចសន្យាដែលបានប្រមូល) និង

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ និង១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ក) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

### *(ii) ការចាត់ចំណាត់ថ្នាក់ (ត)*

**ការវាយតម្លៃគំរូអាជីវកម្ម (ត)**

- ភាពញឹកញាប់ បរិមាណ និងរយៈពេលនៃការលក់ក្នុងគ្រាមុន មូលហេតុនៃការលក់នោះ និងការរំពឹងទុកអំពីសកម្មភាពលក់នាពេលអនាគត ។ ទោះជាយ៉ាងណាក៏ដោយ ព័ត៌មានអំពីសកម្មភាពលក់មិនត្រូវបានចាត់ទុកថាដាច់ដោយឡែកឡើយ ប៉ុន្តែជាផ្នែកមួយនៃការវាយតម្លៃទូទៅ អំពីរបៀបដែលធ្វើឲ្យសម្រេចបាននូវគោលបំណងក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ក្រុមហ៊ុន។

ទ្រព្យសកម្មហិរញ្ញវត្ថុសម្រាប់ការជួញដូរ ឬចាត់ចែង ហើយដែលលទ្ធផលត្រូវបានវាយតម្លៃតាមមូលដ្ឋានតម្លៃសមស្រប ត្រូវបានវាស់វែងតាម FVTPL ព្រោះទ្រព្យសកម្មទាំងនោះមិនមែនសម្រាប់ប្រមូលសាច់ប្រាក់តាមកិច្ចសន្យា ឬមិនមែនសម្រាប់ទាំងការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា និងសម្រាប់លក់ឡើយ។

*ការវាយតម្លៃថាតើលំហូរទឹកប្រាក់តាមកិច្ចសន្យាគឺសម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់*

ចំពោះគោលបំណងនៃការវាយតម្លៃនេះ "ប្រាក់ដើម" គឺជាតម្លៃសមស្របនៃទ្រព្យសកម្មហិរញ្ញវត្ថុនៅពេលទទួលស្គាល់ជាលើកដំបូង ។ "ការប្រាក់" គឺជាតម្លៃតបស្នងមួយសម្រាប់ពេលវេលានៃការប្រើប្រាស់ទឹកប្រាក់សម្រាប់រយៈពេលណាមួយ និងសម្រាប់ហានិភ័យដែលពាក់ព័ន្ធនឹងបរិមាណប្រាក់ដើមនៅជាប់ជំពាក់ក្នុងអំឡុងពេលជាក់លាក់មួយ និងសម្រាប់ការចំណាយរួមទាំងហានិភ័យក្នុងការផ្តល់កម្ចីជាមូលដ្ឋានផ្សេងៗទៀត (ដូចជាហានិភ័យសាច់ប្រាក់ងាយស្រួល និងចំណាយរដ្ឋបាល) រួមទាំងប្រាក់ចំណេញ ។

ដើម្បីវាយតម្លៃថាតើលំហូរទឹកប្រាក់តាមកិច្ចសន្យាគឺសម្រាប់តែទូទាត់ប្រាក់ដើម និងការប្រាក់ ក្រុមហ៊ុនត្រូវពិចារណាលក្ខខណ្ឌកិច្ចសន្យារបស់ឧបករណ៍ហិរញ្ញវត្ថុ រួមបញ្ចូលការវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុមានលក្ខខណ្ឌកិច្ចសន្យាដែលអាចផ្លាស់ប្តូរពេលវេលា ឬចំនួនលំហូរទឹកប្រាក់តាមកិច្ចសន្យាដែលអាចធ្វើឲ្យខុសពីលក្ខខណ្ឌនៃការទូទាត់ប្រាក់ដើម និងការប្រាក់ ។

ក្នុងការវាយតម្លៃ ក្រុមហ៊ុនពិចារណាលើ៖

- ព្រឹត្តិការណ៍ជាយថាភាពដែលអាចផ្លាស់ប្តូរចំនួន និងរយៈពេលនៃលំហូរទឹកប្រាក់
- លក្ខខណ្ឌពិសេស
- លក្ខខណ្ឌសងប្រាក់មុនកាលកំណត់ និងការពន្យាពេលសង
- លក្ខខណ្ឌដែលកម្រិតក្រុមហ៊ុនក្នុងការទាមទារមកវិញនូវសាច់ប្រាក់ពីទ្រព្យសកម្មជាក់លាក់ (ដូចជាឥណទានដែលមិនអាចប្រមូលមកវិញបាន) និង
- លក្ខណៈពិសេសដែលកែប្រែតម្លៃតបស្នងអំពីតម្លៃពេលវេលា (ឧទាហរណ៍ ការកំណត់អត្រាការប្រាក់ឡើងវិញតាមកាលកំណត់) ។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ក) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(ii) ការចាត់ចំណាត់ថ្នាក់ (ត)*

*ឥណទានដែលមិនអាចប្រមូលមកវិញបាន*

ក្នុងករណីខ្លះ ឥណទានដែលផ្តល់ដោយក្រុមហ៊ុន ដែលត្រូវបានការពារដោយទ្រព្យដាក់ធានារបស់អតិថិជន ក៏កំហិតក្រុមហ៊ុនក្នុងការទាមទារសោច់ប្រាក់មកវិញដែរ (ឥណទានដែលមិនអាចប្រមូលមកវិញបាន) ។ ក្នុងករណីនេះ ក្រុមហ៊ុនធ្វើការវិនិច្ឆ័យក្នុងការវាយតម្លៃថាតើឥណទាននោះអាចប្រមូលមកវិញបានតែប្រាក់ដើម និងការប្រាក់ឬទេ ។ ជាទូទៅក្រុមហ៊ុនពិចារណាលើព័ត៌មានខាងក្រោមក្នុងការវិនិច្ឆ័យ៖

- ថាតើកិច្ចសន្យាមានបញ្ជាក់ច្បាស់ពីចំនួន និងកាលបរិច្ឆេទនៃការបង់សងកម្ចីដែរ ឬទេ
- តម្លៃសមស្របនៃទ្រព្យបញ្ចាំពាក់ព័ន្ធនឹងចំនួននៃទ្រព្យសកម្មហិរញ្ញវត្ថុដែលមានការធានា ។
- សមត្ថភាព និងឆន្ទៈរបស់អតិថិជន ក្នុងការទូទាត់សងតាមកិច្ចសន្យា ទោះបីមានឱនភាពនៃតម្លៃទ្រព្យបញ្ចាំក៏ដោយ ។
- ថាតើអតិថិជនគឺជារូបវន្តបុគ្គល ឬជាអង្គភាពប្រតិបត្តិការសំខាន់ ឬជាអង្គភាពដែលមានគោលបំណងពិសេស ។
- ហានិភ័យរបស់ក្រុមហ៊ុនក្នុងការបាត់បង់ទ្រព្យហិរញ្ញវត្ថុ ទាក់ទងនឹងឥណទានដែលមិនអាចប្រមូលមកវិញបាន ។
- ថាតើទ្រព្យដាក់ធានាគឺជាទ្រព្យទាំងអស់ដែលអតិថិជនមាន ឬជាផ្នែកមួយនៃទ្រព្យផ្សេងៗទៀតរបស់អតិថិជន និង
- ថាតើក្រុមហ៊ុនទទួលបានអត្ថប្រយោជន៍ពីទ្រព្យសកម្មនេះ ឬទេ ។

**ការចាត់ចំណាត់ថ្នាក់ឡើងវិញ**

ទ្រព្យសកម្មហិរញ្ញវត្ថុមិនត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញ បន្ទាប់ពីការទទួលស្គាល់តម្លៃដំបូងឡើយ លើកលែងតែក្នុងអំឡុងពេលដែលក្រុមហ៊ុនផ្លាស់ប្តូរគំរូអាជីវកម្មរបស់ខ្លួន ក្នុងការគ្រប់គ្រងទ្រព្យកម្មហិរញ្ញវត្ថុ ។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ក) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

### *(iii) ការឈប់ទទួលស្គាល់*

#### ទ្រព្យសកម្មហិរញ្ញវត្ថុ

ក្រុមហ៊ុនឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលដែលសិទ្ធិក្នុងកិច្ចសន្យាក្នុងការទទួលលំហូរទឹកប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុផុតកំណត់ ឬការផ្ទេរសិទ្ធិទទួលលំហូរទឹកប្រាក់តាមកិច្ចសន្យាក្នុងប្រតិបត្តិការ ដែលហានិភ័យទាំងអស់ និងភាពជាកម្មសិទ្ធិនៃទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានផ្ទេរ ឬក្នុងករណីដែលក្រុមហ៊ុនមិនផ្ទេរ ឬមិនរក្សាទុកនូវរាល់ហានិភ័យ និងភាពជាកម្មសិទ្ធិ ហើយវាមិនរក្សាការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុឡើយ ។

ចំពោះការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ភាពលម្អៀងរវាងតម្លៃយោងរបស់ទ្រព្យសកម្ម (ឬតម្លៃយោងដែលជាចំណែកនៃទ្រព្យសកម្មដែលឈប់ទទួលស្គាល់) និងផលបូកនៃ (i) តម្លៃតបស្នងដែលទទួលបាន (រាប់បញ្ចូលទាំងទ្រព្យសកម្មថ្មីដែលទទួលបាន ដកបំណុលថ្មីដែលទទួលយក) និង (ii) ចំណេញ ឬខាតដែលបានទទួលស្គាល់ក្នុង OCI ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ និងខាត ។

#### បំណុលហិរញ្ញវត្ថុ

ក្រុមហ៊ុនឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលកាតព្វកិច្ចក្រោមកិច្ចសន្យាត្រូវបានរំលាយ ឬលុបចោល ឬផុតអាណត្តិ ។

### *(iv) ការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ*

#### ទ្រព្យសកម្មហិរញ្ញវត្ថុ

ប្រសិនបើលក្ខខណ្ឌនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកែប្រែ នោះក្រុមហ៊ុនវាយតម្លៃថាតើលំហូរទឹកប្រាក់នៃទ្រព្យសកម្មដែលបានកែប្រែនោះ មានភាពខុសគ្នាខ្លាំង ឬទេ ។

ប្រសិនបើលំហូរទឹកប្រាក់មានភាពខុសគ្នាខ្លាំង នោះសិទ្ធិតាមកិច្ចសន្យាចំពោះលំហូរទឹកប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុដើម ត្រូវបានចាត់ទុកថាផុតអាណត្តិ ។ ក្នុងករណីនេះទ្រព្យសកម្មហិរញ្ញវត្ថុដើម ត្រូវឈប់ទទួលស្គាល់ (សូមមើល (iii)) ហើយទ្រព្យសកម្មហិរញ្ញវត្ថុថ្មី ត្រូវបានទទួលស្គាល់តាមតម្លៃសមស្របបូកនឹងថ្លៃចំណាយប្រតិបត្តិការ ។ ថ្លៃសេវានានាដែលទទួលបានជាផ្នែកនៃការកែប្រែនេះ ត្រូវបានរាប់បញ្ចូលដូចខាងក្រោម៖

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ក) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

#### *(iv) ការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)*

ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

- ថ្លៃសេវា ដែលត្រូវបានពិចារណាក្នុងការកំណត់តម្លៃសមស្របនៃទ្រព្យសកម្មថ្មី និងថ្លៃសេវាដែលទទួលបានមកវិញលើថ្លៃចំណាយប្រតិបត្តិការដែលកើតឡើង ត្រូវបានរាប់បញ្ចូលក្នុងការវាស់វែងដំបូងនៃទ្រព្យសកម្ម និង
- ថ្លៃសេវាផ្សេងទៀតត្រូវបានរាប់បញ្ចូលក្នុងប្រាក់ចំណេញ និងខាត ដែលជាផ្នែកមួយនៃការចំណេញ ឬខាត លើទ្រព្យសកម្មដែលត្រូវបានឈប់ទទួលស្គាល់ ។

ប្រសិនបើលំហូរទឹកប្រាក់ត្រូវបានកែប្រែនៅពេលដែលអតិថិជនជួបការលំបាកផ្នែកហិរញ្ញវត្ថុ នោះគោលបំណងនៃការកែប្រែជាទូទៅ គឺដើម្បីទទួលបានមកវិញជាអតិបរមាលើលក្ខខណ្ឌនៃកិច្ចសន្យាដើម ជាជាងបង្កើតទ្រព្យសកម្មថ្មីដែលមានលក្ខខណ្ឌខុសគ្នាខ្លាំង ។ ប្រសិនបើក្រុមហ៊ុនមានគម្រោង កែប្រែទ្រព្យសកម្មហិរញ្ញវត្ថុតាមរបៀបមួយ ដែលអាចនាំឲ្យមានការលើកលែងចំពោះលំហូរទឹកប្រាក់ ទ្រព្យសកម្មនោះ ត្រូវបានយកមកពិចារណាជាមុន ថាតើផ្នែកមួយនៃទ្រព្យសកម្មគួរតែត្រូវបានលុបចេញពីបញ្ជីមុនពេលធ្វើការកែប្រែ ឬទេ (សូមមើលខាងក្រោមសម្រាប់គោលនយោបាយការលុបចេញពីបញ្ជី) ។ វិធីសាស្រ្តនេះជះឥទ្ធិពលដល់លទ្ធផលនៃការវាយតម្លៃបរិមាណ ហើយក្នុងករណីនេះមានន័យថា លក្ខណៈវិនិច្ឆ័យនៃការឈប់ទទួលស្គាល់ទ្រព្យជាទូទៅមិនអាចអនុវត្តបាននោះទេ ។

ប្រសិនបើការកែតម្រូវទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានវាស់វែងតាមតម្លៃដករំលស់ ឬ FVOCI មិនបណ្តាលឲ្យមានការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុទេនោះ នោះក្រុមហ៊ុននឹងគណនាឡើងវិញនូវតម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុជាមុន ដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពដំបូងនៃទ្រព្យសកម្ម និងទទួលស្គាល់លទ្ធផលនៃការកែតម្រូវ ជាចំណេញ ឬខាត ។ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានអត្រាអថេរ អត្រាការប្រាក់ប្រសិទ្ធភាពដែលប្រើដើម្បីគណនាចំណេញ ឬខាតពីការកែតម្រូវ ត្រូវបានកែប្រែដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន នៅពេលដែលធ្វើការកែតម្រូវ ។ រាល់ការចំណាយ ឬថ្លៃសេវាដែលកើតឡើង និងថ្លៃសេវាទទួលបានដែលជាផ្នែកមួយនៃការកែតម្រូវទាក់ទងនឹងតម្លៃយោងដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានធ្វើការកែតម្រូវ ត្រូវបានរំលស់ផ្អែកលើរយៈពេលដែលនៅសល់ នៃទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកែតម្រូវនោះ ។

ប្រសិនបើការកែតម្រូវនេះ ត្រូវបានធ្វើឡើងដោយសារតែអតិថិជនជួបការលំបាកផ្នែកហិរញ្ញវត្ថុ នោះចំណេញ ឬខាតត្រូវបានបង្ហាញជាមួយគ្នានឹងការខាតបង់លើឱនភាពនៃតម្លៃ នៃទ្រព្យសកម្ម ។ ក្នុងករណីផ្សេងទៀត វាត្រូវបានបង្ហាញជាចំណូលការប្រាក់ ដែលគណនាដោយប្រើវិធីសាស្រ្តអត្រាការប្រាក់ប្រសិទ្ធភាព ។

# អេសអេសអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ និង១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ក) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

### *(iv) ការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)*

#### បំណុលហិរញ្ញវត្ថុ

ធនាគារ ឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលលក្ខខណ្ឌរបស់វាត្រូវបានកែតម្រូវ ហើយលំហូរទឹកប្រាក់នៃបំណុលដែលបានកែតម្រូវនោះមានភាពខុសគ្នាខ្លាំង ។ ក្នុងករណីនេះ បំណុលហិរញ្ញវត្ថុថ្មី ត្រូវបានទទួលស្គាល់តាមតម្លៃសមស្រប ។ ភាពលម្អៀងរវាងតម្លៃយោងនៃបំណុលហិរញ្ញវត្ថុដែលឈប់ទទួលស្គាល់ និងតម្លៃតបស្នង ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ និងខាត ។

តម្លៃតបស្នងរួមមានទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុដែលបានផ្ទេរ (ប្រសិនបើមាន) និងការទទួលយកបំណុល រួមទាំងបំណុលហិរញ្ញវត្ថុដែលបានកែតម្រូវថ្មី ។

ប្រសិនបើការកែតម្រូវបំណុលហិរញ្ញវត្ថុនេះមិនត្រូវបានទទួលស្គាល់ទេ នោះរំលស់ថ្លៃដើមរបស់បំណុលត្រូវគណនាឡើងវិញដោយធ្វើអប្បហារលំហូរទឹកប្រាក់ដែលបានកែប្រែ តាមអត្រាការប្រាក់ប្រសិទ្ធភាពដំបូង ហើយលទ្ធផលនៃការចំណេញ ឬខាត ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ និងខាត ។ សម្រាប់បំណុលហិរញ្ញវត្ថុមានអត្រាអថេរ អត្រាការប្រាក់ប្រសិទ្ធភាពដំបូងដែលប្រើដើម្បីគណនាចំណេញ ឬខាតពីការកែតម្រូវ ត្រូវបានកែប្រែដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន នៅពេលដែលធ្វើការកែតម្រូវ ។ រាល់ការចំណាយ និងថ្លៃសេវាដែលកើតមាន ត្រូវបានទទួលស្គាល់ជាការ កែតម្រូវទៅលើតម្លៃយោងនៃបំណុល និងរំលស់តាមរយៈពេលដែលនៅសល់នៃបំណុលហិរញ្ញវត្ថុដែលបានកែតម្រូវ ដោយគណនាអត្រាការប្រាក់ប្រសិទ្ធភាពឡើងវិញលើឧបករណ៍ហិរញ្ញវត្ថុ ។

### *(v) ការកាត់កង*

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ អាចត្រូវកាត់កងគ្នាបាន និងត្រូវបង្ហាញជាចំនួនសុទ្ធនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ លុះត្រាតែក្រុមហ៊ុនមានសិទ្ធិតាមច្បាប់ដើម្បីធ្វើការកាត់កងគ្នាបាន និងមានបំណងធ្វើការទូទាត់ដោយផ្អែកលើមូលដ្ឋានចំនួននៅសល់សុទ្ធ ឬក៏ទទួលស្គាល់ទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ក) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(vi) ការវាស់វែងតម្លៃសមស្រប*

តម្លៃសមស្រប គឺជាថ្លៃដែលនឹងទទួលបានដោយការលក់ទ្រព្យសកម្ម ឬថ្លៃដែលបានទូទាត់ចំពោះការផ្ទេរបំណុលនៅក្នុងប្រតិបត្តិការធម្មតា រវាងអ្នកចូលរួមក្នុងទីផ្សារ នាកាលបរិច្ឆេទនៃការវាស់វែងនៅក្នុងទីផ្សារគោល ឬក្នុងករណីមិនមានទីផ្សារគោល គឺយកទីផ្សារជាអាទិភាពបំផុត ដែលក្រុមហ៊ុនអាចកំណត់រកបាននៅកាលបរិច្ឆេទនៃការវាស់វែងនោះ ។ តម្លៃសមស្របរបស់បំណុលឆ្លុះបញ្ចាំងពីហានិភ័យនៃការមិនអនុវត្តកាតព្វកិច្ច ។

ក្រុមហ៊ុនវាស់វែងតម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុមួយ ដោយប្រើសម្រង់តម្លៃនៅក្នុងទីផ្សារសកម្មរបស់ឧបករណ៍នោះ ប្រសិនបើមាន ។ ទីផ្សារមួយចាត់ទុកជាទីផ្សារសកម្ម ប្រសិនបើប្រតិបត្តិការរបស់ទ្រព្យសកម្ម ឬបំណុល កើតឡើងញឹកញាប់ ហើយទំហំប្រតិបត្តិការមានភាពគ្រប់គ្រាន់ក្នុងការផ្តល់ព័ត៌មានតម្លៃជាទៀងទាត់ ។

ប្រសិនបើពុំមានសម្រង់តម្លៃនៅក្នុងទីផ្សារសកម្មទេ នោះក្រុមហ៊ុនត្រូវប្រើបច្ចេកទេសវាយតម្លៃណាដែលអាចប្រើប្រាស់ធាតុចូលដែលអាចអង្កេតបានជាអតិបរមា និងកាត់បន្ថយនូវការប្រើប្រាស់ធាតុចូលដែលមិនអាចអង្កេតបាន ។ បច្ចេកទេសវាយតម្លៃដែលបានជ្រើសរើស ត្រូវរួមបញ្ចូលនូវកត្តាទាំងអស់ដែលអ្នកចូលរួមក្នុងទីផ្សារនឹងពិចារណានៅក្នុងការកំណត់ថ្លៃ ។

ភស្តុតាងដ៏ល្អបំផុតសម្រាប់តម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុមួយ នៅពេលទទួលស្គាល់ជាលើកដំបូង ជាទូទៅគឺជាថ្លៃប្រតិបត្តិការ មានន័យថា ជាតម្លៃសមស្របនៃផលតបស្នងបានផ្តល់ឲ្យ ឬបានទទួល ។ ប្រសិនបើក្រុមហ៊ុនកំណត់ថា តម្លៃសមស្របនៅពេលទទួលស្គាល់ជាលើកដំបូង ខុសពីតម្លៃប្រតិបត្តិការ ហើយតម្លៃសមស្របនេះពុំមានភស្តុតាងមកបញ្ជាក់ តាមរយៈសម្រង់តម្លៃក្នុងទីផ្សារសកម្មចំពោះទ្រព្យសកម្ម ឬបំណុលដែលស្រដៀងគ្នា ឬក៏តាមរយៈបច្ចេកទេសវាយតម្លៃ ដែលក្នុងនោះធាតុចូលដែលមិនអាចអង្កេតបានពាក់ព័ន្ធនឹងការវាស់វែង ត្រូវបានសន្មត់ថាមិនសារវន្ត ដូច្នេះឧបករណ៍ហិរញ្ញវត្ថុត្រូវវាស់វែងជាលើកដំបូងតាមតម្លៃសមស្រប ដោយកែតម្រូវតាមរយៈការពន្យារនូវភាពខុសគ្នារវាងតម្លៃសមស្របនៅពេលទទួលស្គាល់ជាលើកដំបូង និងថ្លៃប្រតិបត្តិការ ។ បន្ទាប់មកទៀត ភាពខុសគ្នានោះគឺត្រូវទទួលស្គាល់នៅក្នុងចំណេញ ឬខាត ផ្អែកលើអាយុកាលរបស់ឧបករណ៍នោះ ក៏ប៉ុន្តែមិនឲ្យយូរជាងការវាយតម្លៃតាមរយៈទិន្នន័យទីផ្សារដែលអាចអង្កេតបាន ឬនៅពេលបញ្ចប់ប្រតិបត្តិការនោះទេ ។

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ និង១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

### ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ក) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(vi) ការវាស់វែងតម្លៃសមស្រប (ត)*

ប្រសិនបើទ្រព្យសកម្ម ឬបំណុលដែលត្រូវបានវាស់វែងតាមតម្លៃសមស្រប មានតម្លៃលក់ និងតម្លៃទិញ នោះក្រុមហ៊ុនវាស់វែងទ្រព្យសកម្ម និងស្ថានភាពវែងតាមតម្លៃលក់ ហើយវាស់វែងបំណុល និងស្ថានភាពខ្លីតាមតម្លៃទិញ ។

សំណុំទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដែលមានហានិភ័យទីផ្សារ និងហានិភ័យឥណទាន ដែលត្រូវបានចាត់ចែងដោយក្រុមហ៊ុន តាមមូលដ្ឋានចំនួនសុទ្ធដែលមានហានិភ័យទីផ្សារ ឬហានិភ័យឥណទាន ត្រូវបានវាស់វែងតាមមូលដ្ឋាននៃតម្លៃ ដែលនឹងទទួលបានដោយការលក់ទ្រព្យសកម្មដែលមានស្ថានភាពវែង (ឬការទូទាត់សងក្នុងការផ្ទេរទ្រព្យសកម្មសុទ្ធដែលមានស្ថានភាពខ្លី) សម្រាប់ហានិភ័យជាក់លាក់ ។ ការកែតម្រូវត្រឹមកម្រិតទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ មានន័យថា ការកែតម្រូវតម្លៃលក់-ទិញ ឬការកែតម្រូវហានិភ័យឥណទាន ដែលឆ្លុះបញ្ចាំងពីការវាស់វែងតាមមូលដ្ឋានតម្លៃសុទ្ធ គឺត្រូវបានបែងចែកតាមទ្រព្យសកម្ម និងបំណុលនីមួយៗ តាមមូលដ្ឋានការកែតម្រូវហានិភ័យដែលពាក់ព័ន្ធ នៃឧបករណ៍ហិរញ្ញវត្ថុនីមួយៗ នៃទ្រព្យសកម្ម និងបំណុលនោះ ។

តម្លៃសមស្របនៃបំណុលហិរញ្ញវត្ថុមានលក្ខណៈអាចទាមទារសងតាមតម្រូវការ (ឧទាហរណ៍ ប្រាក់បញ្ញើចរន្ត) គឺមិនត្រូវតិចជាងចំនួនទឹកប្រាក់ដែលត្រូវបង់តាមតម្រូវការទេ គឺត្រូវធ្វើអប្បហារចាប់ពីថ្ងៃដំបូងដែលចំនួនទឹកប្រាក់អាចត្រូវបានបង់ ។

ក្រុមហ៊ុនទទួលស្គាល់ការផ្ទេររវាងកម្រិតនៃឋានានុក្រមតម្លៃសមស្រប នៅចុងការិយបរិច្ឆេទនៃរបាយការណ៍អំឡុងពេលដែលការផ្លាស់ប្តូរបានកើតឡើង ។

*(vii) ឱនភាពនៃតម្លៃ*

ក្រុមហ៊ុនទទួលស្គាល់សំវិធានធនលើការបាត់បង់ ECL ចំពោះឧបករណ៍ហិរញ្ញវត្ថុ ដែលមិនបានវាស់វែងតាម FVTPL ដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុ គឺជាឧបករណ៍បំណុល និង
- កិច្ចសន្យាឥណទានដែលបានបោះផ្សាយ ។

ពុំមានការខាតបង់លើឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់នៅក្នុងការវិនិយោគមូលធនឡើយ ។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ក) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

#### *(vii) ឱនភាពនៃតម្លៃ (ត)*

ក្រុមហ៊ុនវាស់វែងសំវិធានធនលើការខាតបង់ តាមចំនួនដែលស្មើនឹង ECL លើកលែងគណនីខាងក្រោម ដែលត្រូវវាស់វែងតាម ECL 12 ខែ ៖

- ការវិនិយោគលើមូលបត្របំណុល ដែលត្រូវបានកំណត់ថាមានហានិភ័យឥណទានទាបនាកាលបរិច្ឆេទរាយការណ៍ និង
- ឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត (ក្រៅពីភតិសន្យាត្រូវទទួល) ដែលហានិភ័យឥណទានមិនបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង ។

ECL ១២ ខែ គឺជាផ្នែកនៃ ECL ដែលបណ្តាលមកពីព្រឹត្តិការណ៍ខកខានសងប្រាក់ក្នុងរយៈពេល ១២ ខែ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ ។ ឧបករណ៍ហិរញ្ញវត្ថុដែលបានទទួលស្គាល់តាម ECL ១២ ខែ ត្រូវបានចាត់ទុកជា "ឧបករណ៍ហិរញ្ញវត្ថុស្ថិតក្នុងដំណាក់កាលទី ១" ។

ECL មួយអាយុកាល (Life-time ECL) គឺជា ECL ដែលអាចបណ្តាលមកពីព្រឹត្តិការណ៍ខកខានសងប្រាក់ ក្នុងរយៈពេលនៃអាយុកាលរំពឹងទុក (expected life) នៃឧបករណ៍ហិរញ្ញវត្ថុ ។ ឧបករណ៍ហិរញ្ញវត្ថុដែលបានទទួលស្គាល់តាម ECL ពេញមួយអាយុកាល ប៉ុន្តែមិនមែនជាឥណទានដែលមានឱនភាពនៃតម្លៃ (credit-impaired) ត្រូវបានចាត់ទុកជា "ឧបករណ៍ហិរញ្ញវត្ថុស្ថិតក្នុងដំណាក់កាលទី ២" ។

នៅកាលបរិច្ឆេទនៃរបាយការណ៍ ក្រុមហ៊ុនវាយតម្លៃថាតើហានិភ័យឥណទាននៃឧបករណ៍ហិរញ្ញវត្ថុ បានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង។ នៅពេលដែលហានិភ័យឥណទានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង សំវិធានធនលើការបាត់បង់ត្រូវបានវាស់វែង តាមតម្លៃស្មើនឹងអាយុកាលនៃ ECL ។

នៅពេលកំណត់ថាតើហានិភ័យឥណទាននៃទ្រព្យសកម្មហិរញ្ញវត្ថុ បានកើនឡើងជាសារវន្តចាប់តាំងពីការទទួលស្គាល់លើកដំបូង និងនៅពេលប៉ាន់ស្មាន ECL នោះក្រុមហ៊ុនពិចារណាលើព័ត៌មានដែលសមហេតុសមផល និងព័ត៌មានគាំទ្រ ដែលពាក់ព័ន្ធ និងអាចរកបាន ដោយមិនចាំបាច់ចំណាយ ឬ ប្រឹងប្រែងខ្ពស់ ។ ព័ត៌មានទាំងនេះរួមបញ្ចូលព័ត៌មានបរិមាណ និងព័ត៌មានគុណភាព និងការវិភាគ ដោយផ្អែកលើបទពិសោធន៍របស់ក្រុមហ៊ុន និងការវាយតម្លៃឥណទាន ព្រមទាំងបញ្ចូលព័ត៌មានដែលប្រមើលអនាគត ។

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ និង១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ក) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(vii) ឱនភាពនៃតម្លៃ (ត)*

ប្រសិនបើហានិភ័យឥណទានមិនបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង ឬ ប្រសិនបើគុណភាពឥណទាននៃឧបករណ៍ហិរញ្ញវត្ថុមានភាពប្រសើរឡើង ដែលបណ្តាលឲ្យគ្មានការកើនឡើងជាសារវន្ត នៃហានិភ័យឥណទានចាប់តាំងពីការទទួលស្គាល់លើកដំបូង សំវិធានធនលើការបាត់បង់ត្រូវបានវាស់វែងតាមតម្លៃស្មើនឹង ECL ១២ ខែ ។

រយៈពេលអតិបរមាដែលត្រូវយកមកពិចារណា ពេលធ្វើការប៉ាន់ស្មាន ECL គឺជារយៈពេលកិច្ចសន្យាអតិបរមា ដែលក្រុមហ៊ុនប្រឈមនឹងហានិភ័យឥណទាន ។

**ការកំណត់នៃការកើនឡើងជាសារវន្តនូវហានិភ័យឥណទាន**

ក្រុមហ៊ុនវាយតម្លៃថាតើមានហានិភ័យឥណទានបានកើនឡើងជាសារវន្ត ឬទេ ចាប់តាំងពីការទទួលស្គាល់លើកដំបូងនៅកាលបរិច្ឆេទរាយការណ៍ ។ ការកំណត់ពីការកើនឡើងនៃហានិភ័យឥណទានផ្អែកជាសំខាន់លើចរិតលក្ខណៈនៃឧបករណ៍ហិរញ្ញវត្ថុ និងអតិថិជន និងតំបន់ភូមិសាស្ត្រ ។

ក្រុមហ៊ុនពិចារណាថាការកើនឡើងនៃហានិភ័យឥណទានជាសារវន្ត កើតឡើងនៅពេលទ្រព្យសកម្មមានការខកខានសងមិនតិចជាងរយៈពេល ៣០ ថ្ងៃ ។ ចំនួនថ្ងៃខកខានត្រូវបានកំណត់ដោយការរាប់ចំនួនថ្ងៃ ចាប់តាំងពីកាលបរិច្ឆេទផុតកំណត់ដំបូងបង្អស់ ដែលការបង់សងទាំងអស់មិនទាន់បានទទួល ។ កាលបរិច្ឆេទផុតកំណត់សង ត្រូវបានកំណត់ដោយមិនពិចារណាទៅលើរយៈពេលអនុគ្រោះណាមួយដែលអាចមានសម្រាប់អតិថិជនឡើយ ។

ប្រសិនបើ មានភស្តុតាងបញ្ជាក់ថាមិនមានការកើនឡើងហានិភ័យឥណទានជាសារវន្តទាក់ទងនឹងការទទួលស្គាល់លើកដំបូងទេ នោះសំវិធានធននៃការបាត់បង់លើឧបករណ៍ហិរញ្ញវត្ថុនឹងត្រូវវាស់វែងតាម ECL ១២ ខែ ។

**និយមន័យនៃការខកខានសង**

ក្រុមហ៊ុនចាត់ទុកទ្រព្យសកម្មហិរញ្ញវត្ថុដែលមានការខកខានសងនៅពេលដែល៖

- អ្នកខ្ចីមិនមានលទ្ធភាពសងចំពោះកាតព្វកិច្ចឥណទានរបស់ខ្លួនទាំងស្រុង ដោយមិនពឹងផ្អែកទៅលើការលក់ទ្រព្យដាក់ធានាដើម្បីទូទាត់សង (ប្រសិនបើមានទ្រព្យដាក់ធានា) ឬ
- ទ្រព្យសកម្មហិរញ្ញវត្ថុខកខានសងលើសពី ៩០ថ្ងៃ ។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ក) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(vii) ឱនភាពនៃតម្លៃ (ត)*

*ការវាស់វែង ECL*

ECL គឺជាការប៉ាន់ស្មានប្រូបាប៊ីលីតេមធ្យមនៃការបាត់បង់ឥណទាន ។ ECL ត្រូវបានវាស់វែងដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនមានឱនភាពនៃតម្លៃនាកាលបរិច្ឆេទរាយការណ៍៖ ជាតម្លៃបច្ចុប្បន្ននៃកង្វះសាច់ប្រាក់ទាំងអស់ (ពោលគឺភាពខុសគ្នារវាងលំហូរទឹកប្រាក់ដែលជំពាក់ក្រុមហ៊ុនស្របតាមកិច្ចសន្យា និងលំហូរទឹកប្រាក់ដែលក្រុមហ៊ុនរំពឹងទុកថានឹងទទួលបាន) ។
- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃនាកាលបរិច្ឆេទរាយការណ៍៖ ជាភាពខុសគ្នារវាងតម្លៃយោងដុល និងតម្លៃបច្ចុប្បន្ននៃលំហូរទឹកប្រាក់ដែលរំពឹងទុកនាពេលអនាគត ។
- កិច្ចសន្យាឥណទានដែលនៅសល់៖ ជាតម្លៃបច្ចុប្បន្ននៃភាពខុសគ្នារវាងលំហូរទឹកប្រាក់តាមកិច្ចសន្យាដែលជំពាក់ក្រុមហ៊ុន ប្រសិនបើអ្នកកាន់កាប់កិច្ចសន្យាឥណទានបានដកឥណទានប្រើ និងលំហូរទឹកប្រាក់ដែលក្រុមហ៊ុនរំពឹងទុកថានឹងទទួលបាន ប្រសិនបើឥណទានត្រូវបានដកប្រើ ។

**ទិន្នន័យ ការសន្មត និងបច្ចេកទេសប្រើសម្រាប់ការវាយតម្លៃឱនភាពនៃតម្លៃ**

សមាសធាតុសំខាន់ៗ ក្នុងការវាស់វែង ECL គឺរចនាសម្ព័ន្ធនៃអញ្ញាតិដូចខាងក្រោម៖

- ប្រូបាប៊ីលីតេនៃការខកខានសង ("PD");
- ការបាត់បង់ដែលបណ្តាលមកពីការខកខានសង ("LGD") និង
- ទំហំនៃការខកខានសង ("EAD")

ECL សម្រាប់សមតុល្យក្នុងដំណាក់កាលទី១ ត្រូវបានគណនាដោយផលគុណនៃ PD ១២ ខែ នឹង LGD នឹង EAD ។ ECL ពេញអាយុកាល ត្រូវបានគណនាដោយផលគុណនៃ PD ពេញអាយុកាល នឹង LGD នឹង EAD ។

គំរូស្ថិតិត្រូវបានប្រើប្រាស់ដើម្បីវិភាគទិន្នន័យប្រមូលបាន រួចបង្កើតនូវការប៉ាន់ស្មាន Lifetime PD ដែលនៅសល់ និងថាតើសមតុល្យទាំងនោះរំពឹងថាប្រែប្រួលយ៉ាងណាលើរយៈពេលនោះ ។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ក) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(vii) ឱនភាពនៃតម្លៃ (ត)*

**ទិន្នន័យ ការសន្មត និងបច្ចេកទេសប្រើសម្រាប់ការវាយតម្លៃឱនភាពនៃតម្លៃ (ត)**

LGD គឺជាតវិយាបទនៃភាពអាចបាត់បង់ប្រសិនបើមានការយខកខាន ។ ក្រុមហ៊ុនប៉ាន់ស្មានលក្ខខណ្ឌ LGD យោងតាមប្រវត្តិនៃអត្រាការប្រមូលត្រលប់ពីអតិថិជនខកខានសង ។ គំរូ LGD ត្រូវបានពិចារណាលើរចនាសម្ព័ន្ធអទិភាពនៃការទាមទារសំណង វិស័យដែលអតិថិជនស្ថិតនៅ ចំណាយលើការប្រមូលពីទ្រព្យបញ្ចាំ គឺជាផ្នែកយ៉ាងសំខាន់នៃទ្រព្យសកម្មហិរញ្ញវត្ថុ ។ សម្រាប់ឥណទានដែលការពារដោយទ្រព្យ អនុបាតឥណទានធៀបនឹងតម្លៃទ្រព្យបញ្ចាំ ("LTV") គឺជាលក្ខខណ្ឌមួយក្នុងការកំណត់ LGD ។ ការប៉ាន់ស្មាន LGD ត្រូវបានវាស់វែងសម្រាប់វិស័យផ្សេងៗគ្នា ហើយសម្រាប់ឥណទានគេហដ្ឋាន គឺអាស្រ័យលើការប្រែប្រួលតម្លៃអចលនទ្រព្យ ។ តម្លៃទាំងនោះនឹងត្រូវបានគណនាដោយអប្បហា ដោយផ្អែកលើអត្រាការប្រាក់ប្រសិទ្ធិភាព ។

EAD តំណាងឲ្យតម្លៃសមតុល្យនៅពេលមានការខកខានសង ។ ក្រុមហ៊ុនទាញយក EAD ពីសមតុល្យបច្ចុប្បន្នរបស់អតិថិជន និងភាពអាចប្រែប្រួលលើសមតុល្យបច្ចុប្បន្នពីការបង់សង ដែលអនុញ្ញាតតាមកិច្ចសន្យា និងកើតចេញពីការបង់រំលស់ ។ EAD នៃទ្រព្យសកម្មហិរញ្ញវត្ថុ គឺតម្លៃយោងដុលនៅពេលមានការខកខានសង ។ សម្រាប់កាតព្វកិច្ចឲ្យខ្ចី EAD គឺសមតុល្យអនាគតដែលអាចដកប្រើប្រាស់តាមកិច្ចសន្យា ដែលត្រូវបានប៉ាន់ស្មានតាមការសង្កេតពីប្រវត្តិ និងការព្យាករណ៍នាពេលខាងមុខ ។ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុខ្លះ EAD ត្រូវបានកំណត់ដោយគំរូនៃសមតុល្យដែលអាចកើតឡើងនៅពេលវេលាផ្សេងគ្នា ដោយប្រើបច្ចេកទេសស្ថិតិ ។

ដូចការរៀបរាប់ខាងលើ ដោយផ្អែកលើការប្រើប្រាស់ PD 12 ខែ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដំណាក់កាលទី 1 ធនាគារវាស់វែង ECL ដោយពិចារណាលើហានិភ័យនៃការខូចខាតលើរយៈពេលពេញលេញនៃកិច្ចសន្យា (រួមបញ្ចូលទាំងរយៈពេលពន្យាប្រសិនបើមាន) ដែលមានហានិភ័យលើឥណទាន ទោះបីជាក្នុងគោលបំណងគ្រប់គ្រងហានិភ័យឥណទានក៏ដោយ ធនាគារពិចារណាលើរយៈពេលដែលវែងជាង ។ រយៈពេលដែលវែងបំផុត គឺគិតត្រឹមថ្ងៃដែលក្រុមហ៊ុនមានសិទ្ធិដើម្បីទាមទារការសងត្រឡប់នៃឥណទាន ឬបញ្ចប់កិច្ចសន្យាផ្តល់ឥណទាន ឬការធានា ។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ក) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(vii) ឱនភាពនៃតម្លៃ (ត)*

*ទ្រព្យសកម្មហិរញ្ញវត្ថុរៀបចំឡើងវិញ*

ប្រសិនបើលក្ខខណ្ឌនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចរចា ឬកែតម្រូវ ឬទ្រព្យសកម្មហិរញ្ញវត្ថុដែលមានស្រាប់ ត្រូវបានជំនួសដោយទ្រព្យសកម្មហិរញ្ញវត្ថុថ្មី ដោយសារស្ថានភាពលំបាកផ្នែកហិរញ្ញវត្ថុរបស់អតិថិជន នោះការវាយតម្លៃត្រូវបានធ្វើឡើង ដើម្បីវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុគួរត្រូវឈប់ទទួលស្គាល់ ឬទេ ហើយ ECL ត្រូវបានវាស់វែងដូចខាងក្រោម៖

- ប្រសិនបើការរៀបចំឡើងវិញ មិនមានលទ្ធផលដែលនាំឲ្យមានការមិនទទួលស្គាល់ទ្រព្យសកម្មដែលមានស្រាប់ទេ នោះលំហូរទឹកប្រាក់ដែលរំពឹងទុកថាកើតមានពីទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកែតម្រូវ ត្រូវបានបញ្ចូលនៅក្នុងការគណនាកង្វះខាតនៃសាច់ប្រាក់ពីទ្រព្យសកម្មដែលមានស្រាប់ ។
- ប្រសិនបើការរៀបចំឡើងវិញ មានលទ្ធផលដែលនាំឲ្យមានការមិនទទួលស្គាល់ទ្រព្យសកម្មដែលមានស្រាប់ នោះតម្លៃសមស្របរំពឹងទុកនៃទ្រព្យសកម្មថ្មីនោះ ត្រូវបានចាត់ទុកជាលំហូរទឹកប្រាក់ចុងក្រោយទទួលបានពីទ្រព្យសកម្មហិរញ្ញវត្ថុបច្ចុប្បន្ន នៅពេលដែលមិនទទួលស្គាល់ ។ ចំនួនទឹកប្រាក់នេះត្រូវបានបញ្ចូលទៅក្នុងការគណនាកង្វះខាតសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុបច្ចុប្បន្ន ដែលត្រូវបានធ្វើអប្បហារពីកាលបរិច្ឆេទរំពឹងទុកនៃការមិនទទួលស្គាល់ ទៅកាលបរិច្ឆេទរបាយការណ៍ ដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពដើមនៃទ្រព្យសកម្មហិរញ្ញវត្ថុបច្ចុប្បន្ន ។

*ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃ*

នៅកាលបរិច្ឆេទរបាយការណ៍នីមួយៗ ក្រុមហ៊ុនវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកត់ត្រាតាមរំលស់ថ្លៃដើម និងបំណុលហិរញ្ញវត្ថុដែលបានកត់ត្រាតាម FVOCI មានឱនភាពនៃតម្លៃ ឬទេ (ដែលត្រូវបានកំណត់ជា "ទ្រព្យសកម្មហិរញ្ញវត្ថុដំណាក់កាលទី 3" ។ ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចាត់ទុកថាមានឱនភាពនៃតម្លៃ នៅពេលដែលព្រឹត្តិការណ៍មួយ ឬច្រើនបានកើតឡើង ដែលនាំឲ្យមានផលប៉ះពាល់អវិជ្ជមានទៅលើលំហូរទឹកប្រាក់នាពេលអនាគតដែលរំពឹងទុក នៃទ្រព្យសកម្មហិរញ្ញវត្ថុ ។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ក) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(vii) ឱនភាពនៃតម្លៃ (ត)*

*ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃ*

ភស្តុតាងដែលបញ្ជាក់ថាទ្រព្យសកម្មហិរញ្ញវត្ថុមានឱនភាពនៃតម្លៃ រួមមានទិន្នន័យដែលអាចអង្កេតបានដូចខាងក្រោម៖

- ការលំបាកផ្នែកហិរញ្ញវត្ថុជាខ្លាំងរបស់អតិថិជន ឬអ្នកបោះផ្សាយ
- ការបំពានកិច្ចសន្យា ដូចជាការខកខានមិនបានសង ឬហួសកាលកំណត់
- ការរៀបចំឡើងវិញលើលក្ខខណ្ឌនៃការផ្តល់ឥណទានដល់អតិថិជន ដែលក្រុមហ៊ុនមិនយល់ព្រម
- អតិថិជនទំនងនឹងក្ស័យធន ឬត្រូវរៀបចំហិរញ្ញវត្ថុឡើងវិញជាថ្មី
- ការបាត់បង់ទីផ្សារសកម្មសម្រាប់មូលបត្រដោយសារតែការលំបាកផ្នែកហិរញ្ញវត្ថុ ។

ឥណទានដែលត្រូវបានរៀបចំឡើងវិញ ដោយសារតែភាពមិនប្រក្រតីនៅក្នុងលក្ខខណ្ឌរបស់អតិថិជន ត្រូវបានចាត់ទុកជាឥណទានមានឱនភាពនៃតម្លៃ លុះត្រាតែមានភស្តុតាងបញ្ជាក់ថាហានិភ័យនៃការមិនទទួលបានលំហូរទឹកប្រាក់តាមកិច្ចសន្យាបានថយចុះជាសំខាន់ និងមិនមានសូចនាករផ្សេងទៀតដែលនាំឲ្យមានឱនភាពនៃតម្លៃ ។ បន្ថែមលើនេះ ឥណទានដែលហួសកាលកំណត់សង ៩០ថ្ងៃ ឬលើសពីនេះ ត្រូវបានចាត់ទុកជាឥណទានមានឱនភាពនៃតម្លៃ ទោះបីជានិយមន័យនៃការហួសកាលកំណត់សងដែលច្បាប់បានកំណត់ផ្សេងគ្នាក៏ដោយ ។

**សំវិធានធនសម្រាប់ ECL នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ**

សំវិធានធននៃការបាត់បង់សម្រាប់ ECL ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែងតាមតម្លៃដករំលស់ ជាការកាត់កងពីតម្លៃយោងដុលនៃទ្រព្យសកម្ម ។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ក) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

*(vii) ឱនភាពនៃតម្លៃ (ត)*

#### ការលុបចេញពីបញ្ជី

ឥណទានផ្តល់ដល់អតិថិជនត្រូវបានលុបចេញពីបញ្ជី (មួយផ្នែក ឬទាំងស្រុង) នៅពេលមិនមានការរំពឹងទុកថាអាចប្រមូលបានមកវិញនូវទ្រព្យសកម្មហិរញ្ញវត្ថុនោះទាំងស្រុង ។ ករណីនេះមានជាទូទៅ នៅពេលក្រុមហ៊ុនកំណត់ថាអ្នកខ្ចីពុំមានទ្រព្យសកម្ម ឬប្រភពចំណូលណាដែលអាចបង្កើតបាននូវលំហូរទឹកប្រាក់គ្រប់គ្រាន់ ដើម្បីទូទាត់សងនូវចំនួនដែលត្រូវលុបចេញពីបញ្ជី ។ ការវាយតម្លៃនេះ ត្រូវធ្វើឡើងតាមកម្រិតទ្រព្យសកម្មនីមួយៗ ។

ទឹកប្រាក់ប្រមូលបានមកវិញលើចំនួនដែលបានលុបចេញពីបញ្ជី ត្រូវបញ្ចូលទៅក្នុងខ្ទង់ "ការខាតបង់សុទ្ធពីឱនភាពនៃតម្លៃ ឧបករណ៍ហិរញ្ញវត្ថុ" នៅក្នុងចំណេញ ឬខាត និង OCI ។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានលុបចេញពីបញ្ជី នៅតែតម្រូវឲ្យមានសកម្មភាពទាមទារសងមកវិញ ដើម្បីអនុលោមតាមនីតិវិធីរបស់ក្រុមហ៊ុនក្នុងការប្រមូលទឹកប្រាក់នៅជំពាក់ ។

### (ខ) សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសាច់ប្រាក់ក្នុងដៃ និងសមតុល្យសាច់ប្រាក់ក្នុងធនាគារ ប្រាក់បញ្ញើ និងការវិនិយោគរយៈពេលខ្លី ដែលមានកាលវសាន្តនៅពេលតម្កល់ដំបូងមានរយៈពេល ៣ខែ ឬតិចជាង ដែលអាចប្តូរជាសាច់ប្រាក់ពេលណាក៏បាន ដោយមានហានិភ័យតិចតួចចំពោះការផ្លាស់ប្តូរតម្លៃ ។

### (គ) ដើមទុន

ភាគហ៊ុនធម្មតា ត្រូវបានចាត់ថ្នាក់ជាមូលធន ។ ថ្លៃដើមផ្ទាល់ក្នុងការបញ្ចេញភាគហ៊ុន ត្រូវបានទទួលស្គាល់ដោយកាត់ចេញពីមូលធន បន្ទាប់ពីដកពន្ធរួច ។ ភាគហ៊ុនដទៃទៀតត្រូវបានចាត់ថ្នាក់ជាមូលធន និង/ឬ បំណុល ផ្អែកលើសមាសធាតុសេដ្ឋកិច្ចនៃឧបករណ៍ទាំងនោះ ។ ការបែងចែកទៅអ្នកកាន់កាប់ឧបករណ៍ ហិរញ្ញវត្ថុដែលត្រូវបានចាត់ថ្នាក់ជាឧបករណ៍មូលធន ត្រូវបានទូទាត់ដោយផ្ទាល់ពីមូលធន ។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ឃ) ទុនបម្រុងទូទៅ និងទុនបម្រុងតាមបទប្បញ្ញត្តិ

ទុនបម្រុងទូទៅត្រូវបានអនុវត្តដើម្បីត្រួតពិនិត្យហានិភ័យហិរញ្ញវត្ថុជាទូទៅ ។ ក្រុមប្រឹក្សាភិបាលជាអ្នកសម្រេចក្នុងការប្រើប្រាស់ និងរក្សាទុនបម្រុងទូទៅ ។ ការផ្ទេរប្រាក់ចំណេញរក្សាទុកទៅទុនបម្រុងទូទៅត្រូវអនុម័តដោយក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ។

ទុនបម្រុងតាមបទប្បញ្ញត្តិ ត្រូវបានបង្កើតលើភាពខុសគ្នា រវាងសំវិធានធន ស្របតាម ស.រ.ហ.អ.ក និងសំវិធានធនតាមបទប្បញ្ញត្តិ ស្របតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា លេខ ធ៧-០១៧-៣៤៤ ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៧ និងសារាចរណែនាំ លេខ ធ៧-០១៨-០០១ ស.រ.ឆ.ណ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមភែរមែន សម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ។ ស្របតាមប្រការ ៧៣ គ្រឹះស្ថានត្រូវប្រៀបធៀបសំវិធានធន ដែលគណនាអនុលោមតាមប្រការ ៤៩ ដល់ ប្រការ ៧១ ជាមួយនឹងសំវិធានធនដែលគណនាអនុលោមតាមប្រការ ៧២ និងត្រូវកត់ត្រាដូចខាងក្រោមៈ

(i) ក្នុងករណីដែលសំវិធានធនតាមបទប្បញ្ញត្តិ ដែលគណនាតាមប្រការ 72 ទាបជាងសំវិធានធនដែលគណនាតាមប្រការ 49 ដល់ ប្រការ 71 នោះគ្រឹះស្ថានត្រូវកត់ត្រាសំវិធានធន ដែលត្រូវគណនាតាម ស.រ.ហ.អ.ក និង

(ii) ក្នុងករណីដែលសំវិធានធនតាមបទប្បញ្ញត្តិ ដែលគណនាតាមប្រការ 72 ខ្ពស់ជាងសំវិធានធនដែលគណនាតាមប្រការ 49 ដល់ ប្រការ 71 នោះគ្រឹះស្ថានត្រូវកត់ត្រាសំវិធានធន ដែលត្រូវគណនាតាម ស.រ.ហ.អ.ក និងផ្ទេរចំនួនលម្អៀងនោះពីប្រាក់ចំណេញរក្សាទុក ឬគណនីខាតបង្គរទៅទុនបម្រុងតាមបទប្បញ្ញត្តិ នៅក្នុងមូលធន នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ។

ទុនបម្រុងតាមបទប្បញ្ញត្តិមិនត្រូវបានបញ្ចូលក្នុងការគណនាមូលធនផ្ទាល់សុទ្ធរបស់ក្រុមហ៊ុនឡើយ ។

### (ង) ប្រាក់បញ្ញើនៅធនាគារ

ប្រាក់បញ្ញើនៅធនាគារ ត្រូវបានកត់ត្រាតាមតម្លៃដើម ដកសំវិធានធនដែលមិនអាចប្រមូលមកវិញបាន ។

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ និង១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ច) ប្រាក់តម្កល់តាមច្បាប់

ប្រាក់តម្កល់តាមច្បាប់ ត្រូវបានរក្សាទុកនៅធនាគារជាតិនៃកម្ពុជាស្របតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា និងត្រូវបានកំណត់ជាភាគរយនៃដើមទុនអប្បបរមា និងប្រាក់បញ្ញើរបស់អតិថិជនដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា ។

### (ឆ) ឥណទានផ្តល់ដល់អតិថិជន

ឥណទានផ្តល់ដល់អតិថិជន ដែលបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ រួមបញ្ចូលឥណទានផ្តល់ដល់អតិថិជន ដែលត្រូវបានវាស់វែងតាមរំលស់តម្លៃដើម ។ ឥណទានផ្តល់ដល់អតិថិជនត្រូវបានវាស់វែងលើកដំបូងតាមតម្លៃសមស្រប បូកចំណាយប្រតិបត្តិការដែលកើតឡើងដោយផ្ទាល់ ហើយនាពេលបន្ទាប់ត្រូវកត់ត្រាតាមរំលស់ថ្លៃដើម ដោយប្រើវិធីសាស្រ្តអត្រាការប្រាក់ប្រសិទ្ធភាព ។

### (ជ) ទ្រព្យសកម្មផ្សេងទៀត

ទ្រព្យសកម្មផ្សេងទៀតត្រូវបានកត់ត្រាតាមតម្លៃដើម ដកឱនភាពនៃតម្លៃ ប្រសិនបើមាន ។

### (ឈ) ទ្រព្យ និងបរិក្ខារ

(i) ទ្រព្យ និងបរិក្ខារត្រូវបានកត់ត្រាតាមតម្លៃដើម ដករំលស់បង្គរ និងការបាត់បង់លើអ៊ីមភែរមែនដែលបង្គរ ប្រសិនបើមាន ។ ដោយសារ ទ្រព្យ និងបរិក្ខារមានអាយុកាលប្រើប្រាស់ខុសៗគ្នា ទ្រព្យ និងបរិក្ខារទាំងនោះត្រូវបានបែងចែកទៅតាមប្រភេទដោយឡែកពីគ្នា ។

(ii) រំលស់លើទ្រព្យ និងបរិក្ខារ ត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងប្រាក់ចំណេញ និងខាត ដោយផ្អែកលើមូលដ្ឋានរំលស់ថេរ ដោយគិតទៅតាមអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់ទ្រព្យ និងបរិក្ខារនីមួយៗ ដូចខាងក្រោម៖

| | |
|---|---|
| បរិក្ខារការិយាល័យ និងគ្រឿងសង្ហារឹម | ៣ – ៥ ឆ្នាំ |
| យានយន្ត | ៤ – ៥ ឆ្នាំ |
| បរិក្ខារកុំព្យូទ័រ | ៣ ឆ្នាំ |
| ការកែលម្អអគារជួល - រយៈពេលណាមួយដែលតិចជាង វាងអាយុកាលប្រើប្រាស់ និងថេរវេលានៃកិច្ចសន្យាជួល | ៥ – ១០ ឆ្នាំ |

ទ្រព្យ និងបរិក្ខារមិនត្រូវបានធ្វើរំលស់ឡើយ រហូតដល់ទ្រព្យ និងបរិក្ខារទាំងនោះរួចរាល់សម្រាប់ប្រើប្រាស់ទៅតាមការចង់បានរបស់គណៈគ្រប់គ្រង ។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ឈ) ទ្រព្យ និងបរិក្ខារ (ត)

(iii) ការចំណាយបន្ទាប់ដែលពាក់ព័ន្ធទៅនឹងផ្នែកមួយនៃទ្រព្យ និងបរិក្ខារ ដែលបានទទួលស្គាល់រួចមកហើយ ត្រូវបានបូកបញ្ចូលទៅក្នុងតម្លៃយោងនៃផ្នែកនោះ ប្រសិនបើអាចមានលទ្ធភាពផ្តល់នូវអត្ថប្រយោជន៍ សេដ្ឋកិច្ចនាពេលអនាគតដល់ក្រុមហ៊ុន លើសពីស្តង់ដារដើម នៃទ្រព្យដែលមានស្រាប់ ។ រាល់ការចំណាយបន្តបន្ទាប់ផ្សេងទៀតត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងការិយបរិច្ឆេទដែលបានកើតឡើង ។

(iv) ចំណេញ ឬខាតពីការឈប់ប្រើ ឬការលក់ចេញផ្នែកនៃទ្រព្យ និងបរិក្ខារណាមួយ ត្រូវបានកំណត់ដោយភាពខុសគ្នារវាងសាច់ប្រាក់ទទួលបានពីការលក់ និងតម្លៃយោងនៃទ្រព្យ និងបរិក្ខារនោះ ហើយត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណេញ និងខាត នៅការិយបរិច្ឆេទនៃការឈប់ប្រើ ឬការលក់ចេញ ។

(v) តម្លៃយោងនៃទ្រព្យត្រូវបានកត់ត្រាភ្លាមៗនៅក្នុងតម្លៃដែលអាចប្រមូលមកវិញបាន ប្រសិនបើតម្លៃយោងនៃទ្រព្យ ធំជាងតម្លៃប៉ាន់ស្មានដែលអាចប្រមូលមកវិញបាន ។

### (ញ) ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបី ដែលរួមមានថ្លៃដើមសម្រាប់អាជ្ញាប័ណ្ណកុំព្យូទ័រ ដែលបានទិញ និងថ្លៃដើមពាក់ព័ន្ធផ្សេងទៀត ត្រូវបានកត់ត្រាតាមថ្លៃដើម ដករំលស់បង្គរ និងការខាតបង់លើឱនភាពនៃតម្លៃបង្គរ ប្រសិនបើមាន ។ អាជ្ញាប័ណ្ណកុំព្យូទ័រ ដែលបានទិញត្រូវបានធ្វើមូលធនកម្មតាមមូលដ្ឋានថ្លៃដើម ដែលបានកើតឡើងក្នុងការទិញកម្មវិធីជាក់លាក់នោះមកប្រើប្រាស់ ។

ទ្រព្យសកម្មអរូបីត្រូវបានដករំលស់ទៅតាមការប៉ាន់ស្មានអាយុកាលប្រើប្រាស់ពី ៥ ទៅ ២០ ឆ្នាំ តាមវិធីសាស្ត្ររំលស់ថេរ ។

ថ្លៃដើមពាក់ព័ន្ធនឹងការអភិវឌ្ឍ ឬថែទាំកុំព្យូទ័រ ត្រូវបានទទួលស្គាល់ជាចំណាយនៅពេលដែលកើតឡើង ។

### (ដ) ភតិសន្យា

នៅពេលចាប់ផ្តើមកិច្ចសន្យា ធនាគារធ្វើការវាយតម្លៃថាតើកិច្ចសន្យាមួយមានទម្រង់ជាភតិសន្យាដែរឬទេ ។ កិច្ចសន្យាជាទម្រង់មានភតិសន្យា ប្រសិនបើកិច្ចសន្យាផ្តល់សិទ្ធិគ្រប់គ្រងការប្រើប្រាស់ទ្រព្យសកម្មជាក់លាក់មួយក្នុងរយៈពេលកំណត់មួយ ជាថ្នូរនឹងតម្លៃតបស្នង ។

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ និង១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

### ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

#### (ដ) ភតិសន្យា (ត)

ដើម្បីវាយតម្លៃថាតើកិច្ចសន្យាមានសិទ្ធិគ្រប់គ្រងការប្រើប្រាស់ទ្រព្យដែលបានកំណត់ដែរឬទេ ក្រុមហ៊ុនធ្វើការវាយតម្លៃ ថាតើ៖

- កិច្ចសន្យាមានជាប់ពាក់ព័ន្ធនឹងការប្រើប្រាស់ទ្រព្យដែលបានកំណត់ឬទេ ដែលនេះគួរតែបញ្ជាក់ឲ្យច្បាស់លាស់ ឬជាក់លាក់ ហើយគួរតែបង្ហាញឲ្យឃើញច្បាស់ពីភាពខុសគ្នា ឬបង្ហាញពីសមត្ថភាពទាំងអស់របស់ទ្រព្យដែលខុសគ្នានោះ ។ ប្រសិនបើអ្នកផ្គត់ផ្គង់មានសិទ្ធិផ្តល់ទ្រព្យសកម្មជំនួសជាសារវន្តក្នុងរយៈពេលប្រើប្រាស់ នោះទ្រព្យសកម្មមិនមែនមានលក្ខណៈជាទ្រព្យសកម្មជាក់លាក់នោះទេ
- ក្រុមហ៊ុនមានសិទ្ធិទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ចជាសារវន្ត ពីការប្រើប្រាស់ទ្រព្យសកម្ម ក្នុងរយៈពេលនៃការប្រើប្រាស់ និង
- ក្រុមហ៊ុនមានសិទ្ធិបញ្ជាការប្រើប្រាស់ទ្រព្យ ។ ក្រុមហ៊ុនមានសិទ្ធិនេះនៅពេលដែលក្រុមហ៊ុនមានសិទ្ធិសម្រេចចិត្ត អំពីរបៀប និងគោលបំណងក្នុងការប្រើប្រាស់ទ្រព្យ ។ ក្នុងករណីដែលការសម្រេចចិត្តទាំងអស់អំពីរបៀប និងគោលបំណងនៃការប្រើប្រាស់ទ្រព្យត្រូវបានកំណត់ជាមុន នោះក្រុមហ៊ុនមានសិទ្ធិដឹកនាំការប្រើប្រាស់ទ្រព្យ ប្រសិនបើមាន៖
  - ក្រុមហ៊ុនមានសិទ្ធិធ្វើប្រតិបត្តិការលើទ្រព្យ ឬ
  - ក្រុមហ៊ុនបានរចនាទ្រព្យទៅតាមវិធីដែលកំណត់ជាមុនពីរបៀប និងគោលបំណងដែលទ្រព្យនោះនឹងត្រូវប្រើប្រាស់ ។

គោលនយោបាយនេះអនុវត្តចំពោះកិច្ចសន្យាដែលបានព្រមព្រៀង ឬបានធ្វើការផ្លាស់ប្តូរ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៨ មកប៉ុណ្ណោះ ។

នៅពេលចាប់ផ្តើមកិច្ចសន្យា ឬវាយតម្លៃឡើងវិញលើកិច្ចសន្យាដែលមានភតិសន្យា និងគ្មានភតិសន្យា ក្រុមហ៊ុនបែងចែកតម្លៃតបស្នងនៅក្នុងកិច្ចសន្យាចំពោះសមាសធាតុនៃភតិសន្យានីមួយៗ និងសមាសធាតុដែលមិនមែនជាភតិសន្យា ដោយផ្អែកលើតម្លៃដែលអាចដាក់បានតែម្នាក់ឯង ។ យ៉ាងណាមិញ ចំពោះការជួលដី និងអគារដែលក្រុមហ៊ុនជាភតិកៈ ក្រុមហ៊ុនបានជ្រើសរើសមិនបែងចែកសមាសធាតុមិនមែនភតិសន្យា និងគណនីសម្រាប់សមាធាតុភតិសន្យា និងមិនមែនភតិសន្យា ជាសមាសធាតុភតិសន្យាតែមួយនោះទេ ។

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ និង១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

### ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ជ) ភតិសន្យា (ត)

**ភតិសន្យាក្នុងករណីដែលក្រុមហ៊ុនជាភតិក:**

ការរៀបចំឲ្យមានសិទ្ធិក្នុងការប្រើប្រាស់ទ្រព្យ ប្រសិនបើបំពេញតាមលក្ខខណ្ឌមួយក្នុងចំណោមខាងក្រោម៖

- អ្នកទិញមានសមត្ថភាព ឬសិទ្ធិធ្វើប្រតិបត្តិការលើទ្រព្យ ខណៈពេលដែលទទួលបាន ឬគ្រប់គ្រងលើស ពីបរិមាណដែលមិនសំខាន់ ។
- អ្នកទិញមានសមត្ថភាព ឬសិទ្ធិក្នុងការគ្រប់គ្រងដំណើរការរូបវន្តរបស់ទ្រព្យ ខណៈដែលទទួលបាន ឬ គ្រប់គ្រងលើសពីបរិមាណដែលមិនសំខាន់ ។
- ដំណើរហេតុ និងកាលៈទេសៈបានបង្ហាញថា វាជាគម្លាតដែលភាគីដទៃទៀតនឹងទទួលបានច្រើនជាង បរិមាណដែលមិនសារវន្ត ហើយតម្លៃក្នុងមួយឯកតាមិនត្រូវបានកំណត់ក្នុងមួយឯកតានៃទិន្នផលទេ ហើយក៏មិនស្មើនឹងតម្លៃទីផ្សារបច្ចុប្បន្ន ក្នុងមួយឯកតានៃលទ្ធផលដែរ ។

ក្រុមហ៊ុនទទួលស្គាល់សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម និងបំណុលភតិសន្យា នៅកាលបរិច្ឆេទចាប់ផ្តើម ភតិសន្យា ។ សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្មត្រូវបានវាស់វែងតាមថ្លៃដើមរួមមានថ្លៃដើមដំបូងនៃបំណុល ភតិសន្យា សម្រាប់ការចំណាយភតិសន្យាដែលធ្វើឡើងនៅថ្ងៃចាប់ផ្តើមភតិសន្យា ឬមុនថ្ងៃចាប់ផ្តើម ភតិសន្យា បូកថ្លៃដើមផ្ទាល់ដំបូងដែលបានកើតឡើង និងការប៉ាន់ស្មានចំណាយក្នុងការរុះរើ និងដកចេញ នូវទ្រព្យ ឬស្តារឡើងវិញនូវទ្រព្យសកម្ម ឬទីតាំង ដកប្រាក់លើកទឹកចិត្តភតិសន្យាដែលទទួលបាន ។

សិទ្ធិប្រើប្រាស់ទ្រព្យសកម្មត្រូវបានដករំលស់នាពេលបន្ទាប់ តាមវិធីសាស្ត្ររំលស់ថេរ ចាប់ពីកាលបរិច្ឆេទ ចាប់ផ្តើមភតិសន្យា រហូតដល់ចុងបញ្ចប់នៃអាយុកាលប្រើប្រាស់នៃសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ឬនៅចុង កាលបរិច្ឆេទនៃភតិសន្យាមួយណាកើតមុន ។ អាយុកាលប្រើប្រាស់នៃសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ត្រូវបាន កំណត់តាមមូលដ្ឋានដូចគ្នានឹងទ្រព្យ និងបរិក្ខារ ។ បន្ថែមលើនេះ សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម ត្រូវបាន កាត់បន្ថយជាប្រចាំទៅតាមការខាតបង់ឱនភាពនៃតម្លៃ និងកែតម្រូវសម្រាប់ការវាស់វែងឡើងវិញលើ បំណុលភតិសន្យា ។

ការប៉ាន់ស្មានអាយុកាលប្រើប្រាស់សម្រាប់អំឡុងពេលបច្ចុប្បន្ន មានដូចខាងក្រោម៖

- អគារ និងការិយាល័យសាខា ៣ – ១០ ឆ្នាំ

បំណុលភតិសន្យា ត្រូវបានវាស់វែងដំបូងតាមតម្លៃបច្ចុប្បន្ននៃការទូទាត់ភតិសន្យាដែលមិនទាន់បានបង់ នៅពេលចាប់ផ្តើមភតិសន្យា និងត្រូវបានធ្វើអប្បហារដោយប្រើអត្រាការប្រាក់ជាក់ស្តែងនៅក្នុងភតិសន្យា ឬករណីដែលអត្រាការប្រាក់នោះមិនអាចកំណត់បានភ្លាមៗ ត្រូវធ្វើទៅតាមអត្រាការប្រាក់កម្ចីបន្ថែមរបស់ អ្នកជួល ។

# កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ និង១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ដ) ភតិសន្យា (ត)

#### ភតិសន្យាក្នុងករណីដែលក្រុមហ៊ុនជាភតិក: (ត)

ការទូទាត់ភតិសន្យាដែលបញ្ចូលនៅក្នុងការវាស់វែងបំណុលភតិសន្យារួមមាន៖

- ការទូទាត់ភតិសន្យាថេរ រួមទាំងការទូទាត់ទ្រព្យសកម្មថេរ
- ការប្រែប្រួលនៃការទូទាត់ភតិសន្យា ដោយផ្អែកលើសន្ទស្សន៍ ឬអត្រា នៅការិយបរិច្ឆេទចាប់ផ្តើមភតិសន្យា ។
- ចំនួនដែលរំពឹងថានឹងត្រូវទូទាត់ ក្រោមការធានាតម្លៃនៅសល់ និង
- តម្លៃជាក់ស្តែងក្រោមជម្រើសនៃការទិញ ដែលក្រុមហ៊ុនមានហេតុផលជាក់លាក់ក្នុងការអនុវត្ត ការទូទាត់ភតិសន្យានៅក្នុងអំឡុងពេលដែលមានជម្រើសក្នុងការបន្ត ប្រសិនបើក្រុមហ៊ុនមានហេតុផលជាក់លាក់ក្នុងការបន្ត និងការពិន័យលើការបញ្ចប់ភតិសន្យាមុនកាលកំណត់ លើកលែងតែក្រុមហ៊ុនមានហេតុផលច្បាស់លាស់ថានឹងមិនបញ្ចប់ភតិសន្យាមុនកាលកំណត់ ។

បំណុលភតិសន្យាត្រូវបានវាស់វែងតាមថ្លៃដើមរំលស់ ដោយប្រើវិធីសាស្រ្តអត្រាការប្រាក់ប្រសិទ្ធភាព ។ បំណុលភតិសន្យាត្រូវបានវាស់វែងឡើងវិញនៅពេលមានការកែប្រែរយៈពេលនៃភតិសន្យា ការផ្លាស់ប្តូរការវាយតម្លៃសម្រាប់ជម្រើសក្នុងការទិញទ្រព្យសកម្ម ការប្រែប្រួលការទូទាត់ភតិសន្យានាពេលអនាគតដែលកើតឡើងពីការប្រែប្រួលនៃសន្ទស្សន៍ ឬអត្រាការប្រាក់ ឬប្រសិនបើមានការកែប្រែចំនួនប៉ាន់ស្មានដែលរំពឹងថានឹងត្រូវទូទាត់ ក្រោមការធានាតម្លៃដែលនៅសល់ ។

នៅពេលដែលបំណុលភតិសន្យាត្រូវបានវាស់វែងតាមវិធីសាស្រ្តនេះ ការកែតម្រូវ ត្រូវបានធ្វើឡើងលើតម្លៃចុះបញ្ជីនៃសិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម ឬក៏ទទួលស្គាល់ក្នុងចំណេញ ឬខាត បើសិនជាសិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្មត្រូវបានបញ្ចុះរហូតដល់មានតម្លៃសូន្យ។

#### ភតិសន្យាមានរយៈពេលខ្លី និងមានតម្លៃទាប

ភតិសន្យាមានរយៈពេលខ្លី និងមានតម្លៃទាបក្រុមហ៊ុនបានសម្រេច មិនទទួលស្គាល់សិទ្ធិក្នុប្រើប្រាស់ទ្រព្យសកម្ម និងបំណុលភតិសន្យាសម្រាប់ការជួលម៉ាស៊ីនដែលមានរយៈពេលតិចជាង១២ខែ និងភតិសន្យាលើទ្រព្យដែលមានតម្លៃទាប ដែលរួមមានសម្ភារៈ IT ។ ទទួលស្គាល់ចំណាយលើការជួលទាំងនេះតាមមូលដ្ឋានរំលស់ថេរ ទៅតាមរយៈពេលនៃភតិសន្យា ។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ឋ) ប្រាក់កម្ចី

ប្រាក់កម្ចីត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្រប ដកថ្លៃដើមប្រតិបត្តិការបន្ថែមដោយផ្ទាល់ និងវាស់វែងបន្តបន្ទាប់តាមថ្លៃដើមរំលស់ តាមរយៈការប្រើប្រាស់វិធីសាស្ត្រគណនាការប្រាក់ប្រសិទ្ធភាព។

### (ឌ) អត្ថប្រយោជន៍និយោជិត

*(i) អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី*

អត្ថប្រយោជន៍និយោជិតរយៈពេលខ្លីត្រូវបានចំណាយ នៅពេលដែលសេវាកម្មត្រូវបានផ្តល់ជូន ។ ចំនួនដែលរំពឹងទុកថានឹងត្រូវចំណាយ ត្រូវបានទទួលស្គាល់ជាបំណុល ប្រសិនបើក្រុមហ៊ុនមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលនាពេលបច្ចុប្បន្ន ក្នុងការទូទាត់ចំណាយ ដោយជាលទ្ធផលនៃការងារដែលបានបំពេញរួចមកហើយដោយនិយោជិត ហើយកាតព្វកិច្ចនោះអាចធ្វើការប៉ាន់ស្មានបាន។

*(ii) អត្ថប្រយោជន៍និយោជិតរយៈពេលវែង*

កាតព្វកិច្ចរបស់ក្រុមហ៊ុនចំពោះអត្ថប្រយោជន៍និយោជិតរយៈពេលវែង គឺជាចំណាយលើអត្ថប្រយោជន៍ដែលនិយោជិតត្រូវទទួលបាន ពីការបំពេញការងារក្នុងការិយបរិច្ឆេទកន្លងផុតទៅ និងបច្ចុប្បន្ន ។ អត្ថប្រយោជន៍ និយោជិតរយៈពេលវែង ត្រូវបានធ្វើអប្បហារទៅតម្លៃបច្ចុប្បន្ន ។ ការវាស់វែងសារជាថ្មីត្រូវបានទទួលស្គាល់ក្នុងប្រាក់ចំណេញ និងខាត ដែលចំណាយនេះបានកើតឡើង ។

### (ឍ) សំវិធានធន

សំវិធានធនត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលនាពេលបច្ចុប្បន្ន ដែលជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងផុតទៅ ហើយវាមានលទ្ធភាពដែលតម្រូវឲ្យមានលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ច ក្នុងការបំពេញនូវកាតព្វកិច្ចនោះ។ ប្រសិនបើផលប៉ះពាល់មានលក្ខណៈសារវន្ត សំវិធានធនត្រូវបានកំណត់ដោយអប្បហារលំហូរទឹកប្រាក់ ដែលរំពឹងថានឹងត្រូវទូទាត់នាពេលអនាគត ដោយប្រើអត្រាមុនបង់ពន្ធដែលឆ្លុះបញ្ចាំងពីការប៉ាន់ស្មាននៃតម្លៃពេលវេលា ក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់ចំពោះបំណុលទាំងនោះ ។ អប្បហារនៅសល់ត្រូវបានទទួលស្គាល់ជាថ្លៃដើមហិរញ្ញវត្ថុ ។

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ និង១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ណ) ការប្រាក់

*អត្រាការប្រាក់ប្រសិទ្ធភាព*

ចំណូលការប្រាក់ និងចំណាយការប្រាក់ត្រូវទទួលស្គាល់នៅក្នុងចំណេញ ឬខាត ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព ។ "អត្រាការប្រាក់ប្រសិទ្ធភាព" គឺជាអត្រាដែលអាចធ្វើអប្បហារសាច់ប្រាក់ដែលរំពឹងថានឹងទូទាត់ ឬនឹងត្រូវទទួល តាមរយៈអាយុកាលរំពឹងទុករបស់ឧបករណ៍ហិរញ្ញវត្ថុនោះ ឲ្យមកស្មើនឹង៖

- តម្លៃដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬ
- តម្លៃដករំលស់របស់បំណុលហិរញ្ញវត្ថុ ។

នៅពេលគណនាអត្រាការប្រាក់ប្រសិទ្ធភាពសម្រាប់ឧបករណ៍ហិរញ្ញវត្ថុ ក្រៅពីទ្រព្យដែលបានទិញ ឬទ្រព្យសកម្មដែលត្រូវបានចាត់ទុកថាមានឱនភាពនៃតម្លៃ ក្រុមហ៊ុនធ្វើការប៉ាន់ស្មានលើលំហូរទឹកប្រាក់នាពេលអនាគត ដោយពិចារណារាល់លក្ខខណ្ឌទាំងអស់របស់កិច្ចសន្យាឧបករណ៍ហិរញ្ញវត្ថុ ប៉ុន្តែមិនរាប់បញ្ចូលនូវការខាតបង់ឥណទានដែលរំពឹងទុកនោះទេ (ECL) ។ សម្រាប់ទ្រព្យដែលទិញ ឬទ្រព្យហិរញ្ញវត្ថុដែលបានពីការទម្លាក់ឥណទាន អត្រាការប្រាក់ប្រសិទ្ធភាពត្រូវបានគណនា ដោយប្រើលំហូរទឹកប្រាក់ប៉ាន់ស្មាននាពេលអនាគតរួមបញ្ចូលទាំងការខាតបង់ឥណទានដែលរំពឹងទុក (ECL) ។

ការគណនាអត្រាការប្រាក់ប្រសិទ្ធភាព រួមបញ្ចូលនូវថ្លៃដើមប្រតិបត្តិការ និងកម្រៃទាំងអស់ដែលបានបង់ ឬទទួល ដែលជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាព ។ ថ្លៃដើមប្រតិបត្តិការរួមមានការចំណាយបន្ថែមដែលពាក់ព័ន្ធផ្ទាល់ទៅនឹងការទិញ ឬការបោះផ្សាយទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ។

***តម្លៃដករំលស់ និងតម្លៃយោងដុល***

តម្លៃដករំលស់របស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ គឺជាចំនួនដែលទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងនៅពេលទទួលស្គាល់លើកដំបូង ដកការបង់សងប្រាក់ដើម បូកឬដករំលស់បង្គរ ដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាព ចំពោះភាពខុសគ្នារវាងចំនួនដែលទទួលស្គាល់លើកដំបូង និងចំនួននៅពេលដល់កាលកំណត់ និងត្រូវកែតម្រូវចំពោះសំវិធានធនសម្រាប់ការខាតបង់ឥណទានដែលបានរំពឹងទុក ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ (ឬសំវិធានធនមុនការិយបរិច្ឆេទថ្ងៃទី១ ខែមករា ឆ្នាំ២០១៨) ។

តម្លៃយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ គឺជាតម្លៃដករំលស់របស់ទ្រព្យសកម្មហិរញ្ញវត្ថុ មុនពេលកែតម្រូវសំវិធានធនសម្រាប់ការខាតបង់ឥណទានដែលបានរំពឹងទុក ។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ណ) ការប្រាក់ (ត)

*ការគណនាចំណូលការប្រាក់ និងចំណាយការប្រាក់*

អត្រាការប្រាក់ប្រសិទ្ធភាពរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានគណនានៅពេលទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុជាលើកដំបូង ។ ក្នុងការគណនាចំណូលការប្រាក់ និងចំណាយការប្រាក់ អត្រាការប្រាក់ប្រសិទ្ធភាពត្រូវបានប្រើផ្អែកលើតម្លៃដុលរបស់ទ្រព្យសកម្ម (នៅពេលដែលទ្រព្យសកម្មមិនមែនជាទ្រព្យសកម្មដែលត្រូវបានចាត់ទុកថាមានឱនភាពនៃតម្លៃ) ឬតម្លៃដករំលស់របស់បំណុល ។ អត្រាការប្រាក់ប្រសិទ្ធភាពត្រូវធ្វើការកែប្រែឡើងវិញ ដោយការប៉ាន់ស្មានឡើងវិញនូវលំហូរទឹកប្រាក់របស់ឧបករណ៍ដែលមានអត្រាការប្រាក់ប្រែប្រួល ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូររបស់អត្រាការប្រាក់ទីផ្សារ។ អត្រាការប្រាក់ប្រសិទ្ធភាពក៏ត្រូវធ្វើការកែប្រែឡើងវិញ សម្រាប់ការកែតម្រូវតម្លៃសមស្រប នៅការិយបរិច្ឆេទនៃការដករំលស់នៃការចាប់ផ្តើមធ្វើការកែតម្រូវ ។

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានចាត់ទុកថាមានឱនភាពនៃតម្លៃ បន្ទាប់ពីបានទទួលស្គាល់ជាលើកដំបូង ចំណូលការប្រាក់ត្រូវបានគណនាដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាព ផ្អែកលើតម្លៃដករំលស់របស់ទ្រព្យសកម្មហិរញ្ញវត្ថុ ។ ប្រសិនបើទ្រព្យសកម្មហិរញ្ញវត្ថុលែងមានឱនភាពនៃតម្លៃ នោះការគណនាការប្រាក់ត្រូវផ្អែកលើមូលដ្ឋានតម្លៃដុលវិញ ។

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានចាត់ទុកថាមានឱនភាពនៃតម្លៃ ចាប់តាំងពីទទួលស្គាល់ជាលើកដំបូង ចំណូលការប្រាក់ត្រូវបានគណនាដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពដែលត្រូវបានកែតម្រូវនូវហានិភ័យ ផ្អែកលើតម្លៃដករំលស់នៃទ្រព្យសកម្មហិរញ្ញវត្ថុនោះ ។ ការគណនាចំណូលការប្រាក់នេះមិនត្រូវប្តូរទៅមូលដ្ឋានតម្លៃដុលវិញនោះទេ ទោះបីជាហានិភ័យឥណទានរបស់ទ្រព្យសកម្មនោះ មានភាពប្រសើរក៏ដោយ ។

*ការបង្ហាញ*

ចំណូលការប្រាក់គណនាតាមអត្រាការប្រាក់ប្រសិទ្ធភាព ដែលបានបង្ហាញនៅក្នុងចំណេញ ឬខាត និង OCI រួមបញ្ចូលការប្រាក់លើទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដែលវាស់វែងតាមតម្លៃដករំលស់ ។

ចំណាយការប្រាក់បង្ហាញនៅក្នុងចំណេញ ឬខាត និង OCI រួមបញ្ចូលបំណុលហិរញ្ញវត្ថុ ដែលវាស់វែងតាមតម្លៃដករំលស់ ។

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ និង១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ត) កម្រៃសេវា និងកម្រៃជើងសារ

ចំណូល និងចំណាយកម្រៃសេវានិងកម្រៃជើងសារ ដែលជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាព របស់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ត្រូវបានរួមបញ្ចូលទៅក្នុងអត្រាការប្រាក់ប្រសិទ្ធភាព ។

ចំណូលកម្រៃសេវា និងកម្រៃជើងសារផ្សេងទៀត ត្រូវបានទទួលស្គាល់នៅពេលបានបំពេញសេវាកម្ម ។

កិច្ចសន្យាជាមួយអតិថិជនដែលទទួលស្គាល់ជាឧបករណ៍ហិរញ្ញវត្ថុ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន អាចមានវិសាលភាពដោយផ្នែកនៅក្នុង ស.រ.ហ.អ.ក ៩ និងដោយផ្នែកនៅក្នុង ស.រ.ហ.អ.ក ១៥ ។ ក្នុងករណីនេះ ជាដំបូងក្រុមហ៊ុនត្រូវអនុវត្ត ស.រ.ហ.អ.ក ៩ ដើម្បីបែងចែក និងវាស់វែងផ្នែកនៃកិច្ចសន្យាដែលចាត់ចូលនៅក្នុងវិសាលភាពនៃ ស.រ.ហ.អ.ក ៩ ហើយបន្ទាប់មកអនុវត្ត ស.រ.ហ.អ.ក ១៥ ចំពោះផ្នែកដែលនៅសេសសល់ ។

### (ថ) ឱនភាពនៃតម្លៃរបស់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

តម្លៃយោងនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក្រៅពីទ្រព្យសកម្មសារពើភ័ណ្ឌ ទ្រព្យសកម្មជាប់កិច្ចសន្យា និងទ្រព្យសកម្មជាប់ពន្ធ ត្រូវបានត្រួតពិនិត្យឡើងវិញនៅរាល់កាលបរិច្ឆេទរាយការណ៍នីមួយៗ ដើម្បីកំណត់ថាតើមានសញ្ញាណណាមួយដែលបង្ហាញថា ទ្រព្យសកម្មទាំងនោះមានឱនភាពនៃតម្លៃ ។ ប្រសិនបើមានសញ្ញាណនោះកើតឡើង នោះការប៉ាន់ស្មានលើតម្លៃដែលអាចប្រមូលមកវិញបានរបស់ទ្រព្យសកម្មត្រូវបានធ្វើឡើង ។ ចំពោះទ្រព្យសកម្មអរូបីដែលមានអាយុកាលប្រើប្រាស់មិនកំណត់ ឬមិនទាន់អាចប្រើប្រាស់បាន តម្លៃដែលអាចប្រមូលមកវិញបានត្រូវធ្វើការប៉ាន់ស្មានជារៀងរាល់ឆ្នាំក្នុងពេលដំណាលគ្នា ។ ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ប្រសិនបើតម្លៃយោងរបស់ទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ ធំជាងការប៉ាន់ស្មានតម្លៃដែលអាចប្រមូលមកវិញបាន ។

តម្លៃដែលអាចប្រមូលមកវិញបានរបស់ទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ គឺជាតម្លៃដែលធំជាងរវាងតម្លៃប្រើប្រាស់ និងតម្លៃសមស្រប ដកចំណាយដើម្បីលក់ចេញ ។ ក្នុងការប៉ាន់ប្រមាណតម្លៃប្រើប្រាស់ ការប៉ាន់ស្មានលំហូរទឹកប្រាក់នាពេលអនាគត ត្រូវបានធ្វើអប្បហារទៅតម្លៃបច្ចុប្បន្ន ដោយប្រើអត្រាការប្រាក់មុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងការប៉ាន់ប្រមាណតម្លៃពេលវេលាក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់សម្រាប់ទ្រព្យសកម្មទាំងនោះ ឬឯកតាបង្កើតសាច់ប្រាក់ ។

សម្រាប់គោលបំណងនៃការត្រួតពិនិត្យលើឱនភាពនៃតម្លៃ ទ្រព្យសកម្មត្រូវបានដាក់បញ្ចូលគ្នាជាក្រុមតូចៗ ដែលអាចបង្កើតសាច់ប្រាក់បានពីការបន្តការប្រើប្រាស់ ដោយមិនពឹងផ្អែកខ្លាំងលើលំហូរទឹកប្រាក់នៃទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ ។

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ និង១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ថ) ឱនភាពនៃតម្លៃរបស់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ (ត)

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត ។ ការខាតបង់លើឱនភាពនៃតម្លៃ ដែលទទួលស្គាល់ជាឯកតាបង្កើតសាច់ប្រាក់ ត្រូវបានបម្រុងទុក ដើម្បីកាត់បន្ថយតម្លៃយោងនៃទំនិញរបស់ឯកតា បង្កើតសាច់ប្រាក់ (ក្រុមនៃឯកតាបង្កើតសាច់ប្រាក់) ហើយបន្ទាប់មកដើម្បីកាត់បន្ថយតម្លៃយោង នៃទ្រព្យសកម្មដទៃទៀតនៅក្នុងឯកតាបង្កើតសាច់ប្រាក់ (ក្រុមនៃឯកតាបង្កើតសាច់ប្រាក់) លើមូលដ្ឋានសមាមាត្រ ។

ការខាតបង់លើឱនភាពនៃតម្លៃ ដែលទទួលស្គាល់ក្នុងពេលកន្លងផុតទៅ ត្រូវបានប៉ាន់ប្រមាណរាល់ការិយបរិច្ឆេទនៃការរាយការណ៍ ថាតើមានសញ្ញាណណាមួយដែលការខាតបង់បានថយចុះ ឬលែងមានការខាតបង់តទៅទៀត ។ ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវកត់ត្រាបញ្ច្រាសមកវិញ ប្រសិនបើមានការប្រែប្រួលតម្លៃប៉ាន់ប្រមាណដែលប្រើប្រាស់ដើម្បីកំណត់តម្លៃដែលអាចប្រមូលមកវិញបាន ។ ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានកត់ត្រាបញ្ច្រាសមកវិញ ត្រឹមកម្រិតមួយដែលមិនធ្វើឲ្យតម្លៃយោងរបស់ទ្រព្យសកម្មនេះ លើសពីតម្លៃយោងដករំលស់ ដែលត្រូវកំណត់ក្នុងករណីពុំមានការទទួលស្គាល់ការខាតបង់លើឱនភាពនៃតម្លៃ ។

### (ទ) ពន្ធលើប្រាក់ចំណេញ

ចំណាយពន្ធលើប្រាក់ចំណេញរួមមានពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារ ។ ពន្ធលើប្រាក់ចំណេញត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត លើកលែងតែពន្ធនេះទាក់ទងទៅនឹងធាតុដែលត្រូវទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធន ឬចំណូលលម្អិតផ្សេងៗ ។

#### ពន្ធប្រចាំឆ្នាំ

ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ រួមមានពន្ធដែលត្រូវបង់ឬទទួល លើប្រាក់ចំណេញជាប់ពន្ធប្រចាំឆ្នាំ ដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តមួយភាគធំនៅកាលបរិច្ឆេទតារាងតុល្យការ និងនិយ័តភាពទាំងឡាយទៅលើពន្ធត្រូវបង់ពីឆ្នាំមុនៗ ។

#### ពន្ធពន្យារ

ពន្ធពន្យារត្រូវបានទទួលស្គាល់ដោយផ្អែកលើភាពលម្អៀងបណ្តោះអាសន្ន រវាងតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុល នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងតម្លៃយោងសម្រាប់ការគិតពន្ធ ។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ទ) ពន្ធលើប្រាក់ចំណេញ (ត)

ពន្ធពន្យារ (ត)

ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវទទួលស្គាល់ចំពោះការខាតបង់ពន្ធមិនទាន់បានប្រើប្រាស់ និងភាពលម្អៀងបណ្តោះអាសន្នដែលអាចកាត់កងបាន ត្រឹមកម្រិតដែលប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត អាចប្រើប្រាស់សម្រាប់កាត់កងជាមួយភាពលម្អៀងបណ្តោះអាសន្ននោះបាន ។ ពន្ធពន្យារជាទ្រព្យសកម្មត្រូវបានត្រួតពិនិត្យនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ និងត្រូវបានកាត់បន្ថយក្នុងករណីមិនអាចប្រើប្រាស់នូវអត្ថប្រយោជន៍ពន្ធទាំងនោះបាន ។ ការកាត់បន្ថយនោះត្រូវកត់ត្រាបញ្ច្រាសមកវិញនៅពេលដែលប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតមានលក្ខណៈប្រសើរឡើង ។

ពន្ធពន្យារជាទ្រព្យសកម្មត្រូវវាស់វែងតាមអត្រាពន្ធ ដែលរំពឹងថានឹងត្រូវប្រើចំពោះភាពលម្អៀងបណ្តោះអាសន្ននៅពេលដែលវាអាចប្រើប្រាស់បាន ឬកាត់កងបាន ដោយប្រើអត្រាពន្ធនៅកាលបរិច្ឆេទរាយការណ៍ ។

ការវាស់វែងពន្ធពន្យារជាទ្រព្យសកម្មឆ្លុះបញ្ចាំងនូវពន្ធដែលក្រុមហ៊ុនរំពឹងថាអាចប្រើប្រាស់បាន ឬអាចកាត់កងបាននូវតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុល ។

ពន្ធពន្យារជាទ្រព្យសកម្ម និងពន្ធពន្យារជាបំណុល អាចកាត់កងបានតែក្នុងករណីវាបានបំពេញលក្ខខណ្ឌជាក់លាក់ណាមួយ ។

## ៤. ការប្តូររូបិយប័ណ្ណពីដុល្លារអាមេរិកទៅជាប្រាក់រៀល

របាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញជាប្រាក់រៀល ។ ការប្តូររូបិយប័ណ្ណពីដុល្លារអាមេរិកទៅប្រាក់រៀលត្រូវធ្វើឡើងសម្រាប់ជាការបង្ហាញប៉ុណ្ណោះ ។

ទ្រព្យសកម្ម និងបំណុលត្រូវបានប្តូរតាមអត្រា កាលបរិច្ឆេទនៃរាយការណ៍ ។ ដើមទុន និងគណនីបម្រុងត្រូវបានប្តូរតាមអត្រាប្រវត្តិសាស្ត្រ ។ របាយការណ៍ចំណេញ ឬខាត និងលំហូរទឹកប្រាក់ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក ដោយប្រើប្រាស់អត្រាមធ្យមនៅក្នុងការិយបរិច្ឆេទ ។ ភាពលម្អៀងដែលកើតឡើងពីការប្តូររូបិយប័ណ្ណ ត្រូវកត់ត្រាជា "លម្អៀងពីអត្រាប្តូរប្រាក់" នៅក្នុងរបាយការណ៍ចំណូលលម្អិត ។

## ៤. ការប្តូររូបិយប័ណ្ណពីដុល្លារអាមេរិកទៅជាប្រាក់រៀល (ត)

ក្រុមហ៊ុនប្រើប្រាស់អត្រាប្តូររូបិយប័ណ្ណដូចខាងក្រោម៖

| | | | អត្រាចុងការិយបរិច្ឆេទ | អត្រាមធ្យម |
|---|---|---|---|---|
| ៣១ ធ្នូ ២០១៩ | ១ ដុល្លារអាមេរិក | = | ៤.០៧៥ រៀល | ៤.០៥៥ រៀល |
| ៣១ ធ្នូ ២០១៨ | ១ ដុល្លារអាមេរិក | = | ៤.០១៨ រៀល | ៤.០៤៥ រៀល |
| ១ មករា ២០១៨ | ១ ដុល្លារអាមេរិក | = | ៤.០៣៧ រៀល | មិនប្រើ |

ការប្តូររូបិយប័ណ្ណនេះ មិនអាចបកស្រាយជាតំណាងថា ប្រាក់រៀល បានប្តូរ គួរបានប្តូរ ឬគួរប្តូរនៅពេលអនាគត ទៅជាប្រាក់ដុល្លារអាមេរិក តាមអត្រានេះ ឬអត្រាផ្សេងទៀតឡើយ ។

## ៥. កត្តាសំខាន់ៗតាមរដូវកាល

អាជីវកម្មចម្បងរបស់ក្រុមហ៊ុនគឺផ្តល់សេវាមីក្រូហិរញ្ញវត្ថុ និងសេវាហិរញ្ញវត្ថុពាក់ព័ន្ធ ។ ពុំមានកត្តាសំខាន់ៗតាម រដូវកាលដែលពាក់ព័ន្ធនឹងអាជីវកម្មនេះទេ ។

## ៦. សមតុល្យនៅធនាគារជាតិនៃកម្ពុជា

| | | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | |
|---|---|---|---|---|---|
| | | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៤) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៤) |
| គណនីចរន្ត | | ៥៧០.៩២០.០០៨ | ១៤០.១០៣.០៧០ | ២១១.២៧៤.៦៩៩ | ៥២.៥៨២.០៥៥ |
| ប្រាក់តម្កល់ធានាលើដើមទុន | (ក) | ២២.៤៣៧.៧៤០ | ៥.៥០៦.១៩៤ | ១២.០០០.០០០ | ២.៩៨៦.៥៦១ |
| ប្រាក់បម្រុងកាតព្វកិច្ច | (ខ) | ១៦៤.៦៦១.៧១៣ | ៤០.៤០៧.៧៨២ | ៩៤.២៤៨.០៤៧ | ២៣.៤៥៦.៤៥៨ |
| | | ៧៥៨.០១៩.៤៦១ | ១៨៦.០១៧.០៤៦ | ៣១៧.៥២២.៧៤៦ | ៧៩.០២៥.០៧៤ |

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
## សម្រាប់ដំណាច់ការិយបរិច្ឆេទ ៣ខែ និង១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

## ៦. សមតុល្យនៅធនាគារជាតិនៃកម្ពុជា (ត)

### (ក) ប្រាក់តម្កល់ធានាលើដើមទុន

ប្រាក់តម្កល់ធានាលើដើមទុនត្រូវបានរក្សាទុកនៅធនាគារជាតិនៃកម្ពុជា ដោយអនុលោមទៅតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ៧-០៧-១៦៣ ស្តីពីអាជ្ញាប័ណ្ណនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពីសាធារណជន ចំនួន ១០% នៃដើមទុនចុះបញ្ជី ។

ប្រាក់តម្កល់ធានាលើដើមទុននឹងត្រូវបង្វិលឲ្យក្រុមហ៊ុនវិញ នៅពេលដែល ក្រុមហ៊ុនស្ម័គ្រចិត្តបញ្ចប់អាជីវកម្មរបស់ខ្លួន ហើយមិនមាននៅសល់ប្រាក់បញ្ញើរបស់អតិថិជន។ ប្រាក់តម្កល់ធានាលើដើមទុនរក្សាទុកនៅធនាគារជាតិនៃកម្ពុជា ទទួលបានការប្រាក់តាមអត្រា ៣% ក្នុងមួយឆ្នាំ (ឆ្នាំ២០១៨៖ ៣% ក្នុងមួយឆ្នាំ) ។

### (ខ) ប្រាក់បម្រុងកាតព្វកិច្ច

ប្រាក់បម្រុងកាតព្វកិច្ច គឺជាប្រាក់បម្រុងកាតព្វកិច្ចអប្បបរមា ដែលត្រូវបានគណនាតាមអត្រា ៨% នៃប្រាក់បញ្ញើរបស់អតិថិជន ដោយអនុលោមទៅតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជាលេខ ធ៧-០៧-១៦៣ ស្តីពីអាជ្ញាប័ណ្ណនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើពីសាធារណជន ។

ប្រាក់បញ្ញើនេះប្រែប្រួលតាមកម្រិតនៃប្រាក់បញ្ញើរបស់អតិថិជន។ ប្រាក់បម្រុងកាតព្វកិច្ចពុំទទួលបានការប្រាក់នោះទេ ។

## ៧. សមតុល្យនៅធនាគារនានា - សុទ្ធ

| | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | |
|---|---|---|---|---|
| | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៤) | ពាន់រៀល | ដុល្លារអាមេរិក (កំណត់សម្គាល់ ៤) |
| គណនីចរន្ត | ៣៦.៤៧៣.៤៥២ | ៨.៩៥០.៥៤០ | ៤១.០៥៧.៨១៦ | ១០.២១៨.៤៧១ |
| គណនីសន្សំ | ៤១.៥៩៨.៧០៥ | ១០.២០៨.២៧១ | ៦៨.១៨៥.៤៨២ | ១៦.៩៧០.០០៦ |
| | ៧៨.០៧២.១៥៧ | ១៩.១៥៨.៨១១ | ១០៩.២៤៣.២៩៨ | ២៧.១៨៨.៤៧៧ |
| ដក: ការខាតបង់លើឱនភាពនៃតម្លៃ | (៧៨០.៧២១) | (១៩១.៥៨៧) | (១.០៩២.៤៣៣) | (២៧១.៨៨៥) |
| | ៧៧.២៩១.៤៣៦ | ១៨.៩៦៧.២២៤ | ១០៨.១៥០.៨៦៥ | ២៦.៩១៦.៥៩២ |

# អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុសង្ខេបចន្លោះពេល (ត)
